# រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយជាតិ
# ស្តីពី
# ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ
# ឆ្នាំ២០១៧-២០២៥

**បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី**
**ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៧**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាល

# គោលនយោបាយជាតិស្តីពី ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី

ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៧

**រៀបចំដោយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# មាតិកា


**អារម្ភកថា**

**១- សេចក្តីផ្តើម** ..................... ១

១.១- ភាពចាំបាច់នៃគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ..................... ១

១.២- ទិដ្ឋភាពរួមនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈនៅកម្ពុជានិងក្នុងតំបន់ ..................... ១

១.៣- បញ្ហាប្រឈម ..................... ២

**២- ចក្ខុវិស័យ** ..................... ៤

**៣- គោលបំណងនិងគោលដៅ** ..................... ៥

៣.១- គោលបំណង ..................... ៥

៣.២- គោលដៅ ..................... ៥

**៤- យុទ្ធសាស្ត្រ** ..................... ៦

៤.១- យុទ្ធសាស្ត្រទី១ : ពង្រឹងគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈឱ្យស្របតាមតម្រូវការទីផ្សារការងារក្នុងនិងក្រៅប្រទេស ..................... ៧

៤.២- យុទ្ធសាស្ត្រទី២ : បង្កើនលទ្ធភាពទទួលបានការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈប្រកបដោយសមធម៌សម្រាប់បង្កើតការងារ ..................... ៩

៤.៣- យុទ្ធសាស្ត្រទី៣ : លើកទឹកចិត្តភាពជាដៃគូរវាងរដ្ឋនិងឯកជន និងកៀរគរធនធានពីភាគីពាក់ព័ន្ធឲ្យចូលរួមក្នុងការអភិវឌ្ឍនិងធានានិរន្តរភាពនៃប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ..................... ១១

៤.៤- យុទ្ធសាស្ត្រទី៤ : លើកកម្ពស់អភិបាលកិច្ចក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ..................... ១៣

**៥- ផែនការសកម្មភាព** ..................... ១៥

៥.១- ការបង្កើតយន្តការ ..................... ១៥

៥.២- ការបង្កើតក្របខណ្ឌគតិយុត្ត ..................... ១៦

៥.៣- ការគាំទ្រហិរញ្ញវត្ថុ ..................... ១៦

៥.៤- ការបណ្តុះបណ្តាលធនធានមនុស្ស ..................... ១៦

៥.៥- ដំណើរការអនុវត្តគម្រោង ..................... ១៦

**៦- ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ** ..................... ១៦

**៧- សេចក្តីសន្និដ្ឋាន** ..................... ១៧

**៨- សន្ទានុក្រម** ..................... ១៨

**ឧបសម្ព័ន្ធ តារាងវិធានការគោលនយោបាយ** ..................... ២២

# អារម្ភកថា

ក្នុងបរិបទសកលភាវូបនីយកម្ម ការរីកចម្រើនលូតលាស់ឥតឈប់ឈរនិងការប្រកួតប្រជែង ដើម្បីស្វែងរកឧត្តមភាព គឺទាមទារឲ្យប្រទេសជាតិខិតខំបង្កើនគុណភាពផលិតផលនិងសេវាកម្មរបស់ខ្លួនឲ្យបានកម្រិតអតិបរមា។ សមាហរណកម្មនៅក្នុងបណ្ដាប្រទេសអាស៊ាន តម្រូវឲ្យកម្ពុជាចូលរួមក្នុងកិច្ចសហការជាមួយប្រទេសជិតខាងលើវិស័យអាទិភាពក្នុងការសម្រេចឲ្យបាននូវចក្ខុវិស័យរួមរបស់អាស៊ាន។ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច រាជរដ្ឋាភិបាលយល់ឃើញថា ការកសាងកម្លាំងពលកម្មឲ្យមានសមត្ថភាពនិងអាចមានលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យាកម្រិតខ្ពស់ គឺជាកាតព្វកិច្ចដ៏សំខាន់របស់កម្ពុជាក្នុងការឈានទៅសម្រេចគោលដៅកំណើនសេដ្ឋកិច្ចនិងស្ថិរភាពសង្គមប្រកបដោយចីរភាព។

ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវគោលនយោបាយនិងផែនការសកម្មភាពមួយចំនួនទៀតផងដែរ ក្នុងការដឹកនាំប្រទេសឆ្ពោះទៅរកការអភិវឌ្ឍជាបន្តបន្ទាប់ និងបានប្រែក្លាយពីប្រទេសដែលមានស្ថានភាពអន់ថយខាងសេដ្ឋកិច្ច និងមានអត្រាភាពក្រីក្រខ្ពស់ មកជាប្រទេសមានចំណូលមធ្យមកម្រិតទាប។ ក្នុងរយៈពេលជាងមួយទសវត្សកន្លងមកនេះ កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ ហើយវាក៏នៅតែបន្តកើនសម្រាប់រយៈពេល៥ឆ្នាំចុងក្រោយដែលជាហេតុធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាត្រូវបានចាត់ទុកថាជាសេដ្ឋកិច្ចខ្លាមួយថ្មីនៅតំបន់អាស៊ី។

ឈរលើស្មារតីនេះ ការរៀបចំនិងដាក់ចេញនូវគោលនយោបាយជាតិស្ដីពីការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥ បានគូសបញ្ជាក់ពីភាពចាំបាច់ក្នុងការបង្កើតយុទ្ធសាស្ត្រនៃការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ ដល់កម្លាំងពលកម្មឲ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារជាពិសេស រួមចំណែកក្នុងការអភិវឌ្ឍវិស័យ ឧស្សាហកម្ម និងបង្កើតការងារសមរម្យ ព្រមទាំងធានាគុណភាពនិងផលិតភាពខ្ពស់របស់កម្លាំងពលកម្មដែលអាចប្រកួតប្រជែងប្រសើរជាងមុនជាមួយបណ្ដាប្រទេសក្នុងតំបន់។

នៅប្រទេសកម្ពុជា មានភ្នាក់ងារជាច្រើនដែលបាននិងកំពុងធ្វើការអភិវឌ្ឍជំនាញ ចាប់ពីស្ថាប័នសាធារណៈ ឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ហើយកិច្ចសហការរវាងស្ថាប័នទាំងអស់នេះគឺជាកត្តាគន្លឹះដើម្បីធ្វើឲ្យការអភិវឌ្ឍ កម្លាំងពលកម្មទទួលបានជោគជ័យ ហើយគោលនយោបាយជាតិត្រូវតែដាក់បញ្ចូលស្ថាប័នទាំងអស់នេះ។ គោលបំណងនៃគោលនយោបាយនេះគឺបង្កើតក្របខណ្ឌរួមមួយសម្រាប់ដៃគូទាំងអស់ក្នុងការចូលរួមចំណែកអភិវឌ្ឍសមត្ថភាពកម្លាំងពលកម្មទៅតាមរចនាសម្ព័ន្ធនិងមានលំដាប់លំដោយ ដើម្បីឈានទៅរកគំនិតផ្ដួចផ្ដើមនិងការងារសម្រាប់រយៈពេលយូរអង្វែង។ ដូចនេះរាជរដ្ឋាភិបាលសង្ឃឹមថាជោគជ័យនៃការអនុវត្តគោលនយោបាយនេះនឹងក្លាយជាសារនយោបាយក្នុងការជំរុញការវិនិយោគលើវិស័យសំខាន់ៗដែលជាសសរស្ដម្ភទ្រទ្រង់សេដ្ឋកិច្ចជាតិ តាមរយៈការផ្ដត់ផ្ដង់ឲ្យបានគ្រប់គ្រាន់នូវកម្លាំងពលកម្មប្រកបដោយផលិតភាពខ្ពស់។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមសំដែងនូវការកោតសរសើរចំពោះក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលបានដឹកនាំសម្របសម្រួលរៀបចំគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥ ដ៏មានសារៈសំខាន់នេះឡើងនិងសូមវាយតម្លៃខ្ពស់លើការចូលរួមពីគ្រប់ក្រសួង ស្ថាប័ន ព្រមទាំងដៃគូអភិវឌ្ឍ ជាពិសេស ធនាគារអភិវឌ្ឍន៍អាស៊ីដែលបានគាំទ្រនិងផ្តល់កិច្ចសហការចំពោះកិច្ចខិតខំប្រឹងប្រែងរួមគ្នា រៀបចំគោលនយោបាយជាតិនេះឡើង។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំនិងជឿជាក់លើការប្តេជ្ញាចិត្ត ស្មារតីទទួលខុសត្រូវខ្ពស់ និងកិច្ចសហការប្រតិបត្តិការគ្នាដ៏ល្អរបស់ក្រសួង ស្ថាប័នអនុវត្តនៃរាជរដ្ឋាភិបាល វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាលថានឹងជំរុញការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ឲ្យកាន់តែមានភាពទូលំទូលាយនូវគុណភាព និងភាពប្រកួតប្រជែង ព្រមទាំងបំពេញបាននូវតម្រូវការទីផ្សារការងារដែលមាននាពេលបច្ចុប្បន្ននិងអនាគត។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកក្កដាឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ១- សេចក្ដីផ្ដើម

## ១.១- ភាពចាំបាច់នៃគោលនយោបាយជាតិស្ដីពីការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ

ការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ គឺជាកត្តាមិនអាចខ្វះបានក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងជំរុញឲ្យអ្នកសិក្សាទទួលបាននូវចំណេះដឹង ជំនាញបច្ចេកទេសជាមួយសមត្ថភាពពិតប្រាកដ ដើម្បីក្លាយខ្លួនជាពលករជំនាញ អ្នកបច្ចេកទេស ព្រមទាំងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចជាតិ។ នាពេលថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយជាតិធំៗមួយចំនួនដែលក្នុងនោះរួមមាន **"គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥"** និង **"គោលនយោបាយជាតិស្ដីពីមុខរបរនិងការងារ ឆ្នាំ២០១៥-២០២៥"** ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្ម និងបង្កើតការងារសមរម្យ ព្រមទាំងធានាគុណភាពនិងផលិតភាពខ្ពស់របស់កម្លាំងពលកម្មដែលអាចប្រកួតប្រជែងប្រសើរជាងមុនជាមួយបណ្ដាប្រទេសក្នុងតំបន់។ ដើម្បីចូលរួមសម្រេចគោលដៅរបស់គោលនយោបាយជាតិដែលបានដាក់ចេញខាងលើនេះ **"គោលនយោបាយជាតិស្ដីពីការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ"** ចាំបាច់ត្រូវរៀបចំឡើងដោយកំណត់នូវចក្ខុវិស័យ គោលបំណង គោលដៅ និងយុទ្ធសាស្ត្រឲ្យបានច្បាស់លាស់ក្នុងការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាពខ្ពស់ សមត្ថភាព និងជំនាញឆ្លើយតបទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមនាពេលបច្ចុប្បន្ននិងអនាគត។

## ១.២- ទិដ្ឋភាពរួមនៃការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈនៅកម្ពុជានិងក្នុងតំបន់

នៅក្នុងអាស៊ាន ការអភិវឌ្ឍជំនាញមានការរីកចម្រើនយ៉ាងឆាប់រហ័សដោយសារមានការយល់ឃើញថា វាជាកត្តាមួយដ៏ចាំបាច់សម្រាប់កំណើនសេដ្ឋកិច្ច។ ការផ្លាស់ប្ដូរត្រូវបានគាំទ្រតាមរយៈគោលនយោបាយក្នុងការអភិវឌ្ឍជំនាញដែលជាទូទៅផ្អែកលើតម្រូវការ និងបានដាក់បញ្ចូលទៅគ្រប់ក្រសួង ព្រមទាំងស្ថាប័នពាក់ព័ន្ធទាំងអស់ដែលផ្ដល់ការបណ្ដុះបណ្ដាល។ នៅតាមបណ្ដាប្រទេសមួយចំនួន ការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ ត្រូវបានពង្រីកនិងក្លាយជាអាជ្ញាធរ ឬភ្នាក់ងារឯករាជ្យក្នុងរដ្ឋាភិបាល ព្រមទាំងបានបង្កើតស្ដង់ដាសម្រាប់វិស័យអាទិភាពមួយចំនួន មិនមែនត្រឹមតែបច្ចេកវិទ្យានោះទេ ប៉ុន្តែសម្រាប់សុខាភិបាលនិងជំនាញអាជីវកម្ម ជាពិសេស ជំនាញដែលផ្អែកលើប្រព័ន្ធកុំព្យូទ័រផងដែរ។ អាស៊ានក៏មានតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រឲ្យមានស្ដង់ដាជំនាញក្នុងតំបន់រួមគ្នា ហើយអត្ថប្រយោជន៍ទាំងនេះត្រូវបានមើលឃើញថាមាននៅក្នុងផ្នែកបដិសណ្ឋារកិច្ច ក៏ដូចជាអាជីវកម្មតាមបែបប្រពៃណីផងដែរ។

រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំដ៏ឈ្លាសវៃនិងប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បាននិងកំពុងផ្ដោតការយកចិត្តទុកដាក់យ៉ាងខ្លាំងលើគ្រប់វិស័យ ជាពិសេស ការអភិវឌ្ឍវិស័យការងារ រួមទាំងការបង្កើតការងារ ការពង្រឹងភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ ព្រមទាំងជំរុញការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ ឲ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ ដើម្បីចូលរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ ការលើកស្ទួយជីវភាពប្រជាពលរដ្ឋ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាពដូចបានរំលេចឡើងនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៤-២០១៨ ក៏បានបង្ហាញនូវការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការបណ្ដុះបណ្ដាលធនធានមនុស្សដែលជាកស្ដុតាងច្បាស់លាស់ក្នុងបរិបទនៃការបង្កើតការងារ ដើម្បីបង្កើនល្បឿនកំណើនសេដ្ឋកិច្ច ហើយផែនការយុទ្ធសាស្ត្រនេះក៏បានបែងចែកនូវសកម្មភាពសំខាន់ៗមួយចំនួនសម្រាប់ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដើម្បីអនុវត្តគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេស ទាក់ទងនឹងការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ[១]។

---

[១]ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ជំពូកទី៤ គោលនយោបាយនិងសកម្មភាពអាទិភាព ទំព័រទី៣០៥។

ផលិតផលក្នុងស្រុកសរុប(GDP) របស់កម្ពុជាមានការកើនឡើងទ្វេដងក្នុងរយៈពេល១០ឆ្នាំ (១៩៩៤-២០០៤) និងកើនឡើង៣ដងក្នុងរយៈពេល១៥ឆ្នាំ (១៩៩៤-២០០៩) ហើយនៅឆ្នាំ២០១២ កំណើនសេដ្ឋកិច្ចបានកើនឡើងរហូតដល់៧,៣ភាគរយជាមួយនឹងផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ ដែលបានកើនឡើងពី៧៦០ដុល្លារនៅឆ្នាំ២០០៨មកដល់១៣០០ដុល្លារ នៅឆ្នាំ២០១៦[២]។ តាមរយៈកំណើនសេដ្ឋកិច្ចនេះ ប្រទេសកម្ពុជាបានឈានចេញពីចំណោមក្រុមប្រទេសក្រីក្រមកជាចំណាត់ថ្នាក់ **"ប្រទេសមានចំណូលមធ្យមកម្រិតទាប"** ហើយគោលដៅសេដ្ឋកិច្ចសង្គមរបស់រាជរដ្ឋាភិបាលកម្ពុជា គឺធ្វើការប្រែក្លាយប្រទេសកម្ពុជាទៅជា **"ប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់"** នៅឆ្នាំ២០៣០ និងក្លាយជា **"ប្រទេសអភិវឌ្ឍ"** នៅឆ្នាំ២០៥០។

ក្នុងឆ្នាំ២០១៥ ព្រះរាជាណាចក្រកម្ពុជាមានប្រជាជនសរុបប្រមាណ១៥ ៤០៥ពាន់នាក់ ហើយប្រជាជនស្ថិតក្នុងអាយុធ្វើការបានចំនួន១០ ១១៣ពាន់នាក់ ដែលក្នុងនោះមានកម្លាំងពលកម្មចំនួន៨ ៣៥៩ពាន់នាក់។ ការអប់រំនិងជំនាញរបស់កម្លាំងពលកម្មនៅមានកម្រិតទាប៖ កម្លាំងពលកម្មចំនួន១៣,៥០ភាគរយមិនបានទទួលការអប់រំ ២៧,៨០ភាគរយបានបញ្ចប់ការអប់រំបឋមសិក្សា ១៤ភាគរយបានបញ្ចប់ការសិក្សាកម្រិតអនុវិទ្យាល័យ ៦,៨០ភាគរយបានបញ្ចប់ការសិក្សាកម្រិតវិទ្យាល័យ និង៥,៤០ភាគរយបានបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យ[៣]។ លើសពីនេះគុណភាពរបស់កម្លាំងពលកម្មនៅមានកម្រិត ហើយពិបាកក្នុងការសម្របទៅនឹងការវិវត្តរបស់បច្ចេកវិទ្យាថ្មីៗដោយសារចំណេះដឹង មូលដ្ឋានរបស់កម្លាំងពលកម្មនៅមានកម្រិត។ នាពេលបច្ចុប្បន្ននេះ កម្ពុជាមានគោលបំណងធ្វើការផ្លាស់ប្តូរស្ថានភាពពីប្រទេសដែលមានចំណូលទាបទៅជាប្រទេសដែលមានចំណូលមធ្យមនោះវាតម្រូវឲ្យមានការបង្កើននូវជំនាញសម្រាប់កម្លាំងពលកម្មដែលមានស្រាប់ និងអ្នកដែលត្រៀមចូលធ្វើការ។ តាមរយៈនេះ ចំនួនពលករជំនាញកម្រិតទាបក៏ត្រូវបានថយចុះ ចំណែកពលករជំនាញកម្រិតមធ្យម និងខ្ពស់ដែលមានចំនួនតិចតួចនោះនឹងត្រូវបានកើនឡើងដូចបានបញ្ជាក់ក្នុងពីរ៉ាមីដចំនួនពីរដូចខាងក្រោម៖




ស្ថានភាពប្រទេសដែលមានចំណូលទាប | ស្ថានភាពប្រទេសដែលមានចំណូលមធ្យម

### ១.៣- បញ្ហាប្រឈម

តាមរយៈកិច្ចខិតខំប្រឹងប្រែងយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាលកម្ពុជា និងការចូលរួមរបស់ដៃគូអភិវឌ្ឍបានធ្វើឲ្យការអភិវឌ្ឍជំនាញក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ មានការរីកចម្រើនគួរឲ្យកត់សម្គាល់

[២] បទបង្ហាញស្តីពីវឌ្ឍនភាពនៃម៉ាក្រូសេដ្ឋកិច្ចនៅកម្ពុជា : ដំណើរការរយៈពេល២៥ឆ្នាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅថ្ងៃទី៥ ខែតុលា ឆ្នាំ២០១៦។

[៣] ក្រសួងផែនការឆ្នាំ២០១៦។ ការអង្កេតអំពីសេដ្ឋកិច្ចសង្គមនៅកម្ពុជាឆ្នាំ២០១៥ ទំព័រទី៥១ និងទី៥៣។

ប៉ុន្តែទោះជាយ៉ាងណាក៏វិស័យនេះនៅតែបន្តជួបប្រទះនូវបញ្ហាមួយចំនួនក្នុងស្ថានភាពមានកម្រិតដូចខាងក្រោមៈ

**១.៣.១- គុណភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ មិនទាន់បានឆ្លើយតបទាំងស្រុងទៅនឹងតម្រូវការទីផ្សារការងារនៅឡើយ**

ការនេះបណ្តាលមកពីកង្វះនូវប្រព័ន្ធធានាគុណភាព វិធីសាស្ត្របណ្តុះបណ្តាលនៅមានកម្រិត កង្វះខាតបទពិសោធជាក់ស្តែងរបស់គ្រូបច្ចេកទេសជាមួយវិស័យឧស្សាហកម្ម កង្វះហេដ្ឋារចនាសម្ព័ន្ធ ជម្រើសនៃសម្ភារៈបណ្តុះបណ្តាល បទប្បញ្ញត្តិដែលពាក់ព័ន្ធនៅមិនទាន់មានគ្រប់គ្រាន់ កង្វះប្រព័ន្ធវាយតម្លៃសមត្ថភាព គ្រូបច្ចេកទេស និងសិស្សព្រមទាំងជំនាញរបស់ពលករមុន និងក្រោយពេលចំណាកស្រុកដោយមានការទទួលស្គាល់ពីវិស័យឧស្សាហកម្មពាក់ព័ន្ធ។

**១.៣.២- ការមិនសូវឲ្យតម្លៃទៅលើការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ**

ប្រជាជនមួយចំនួនឲ្យតម្លៃតែលើការអប់រំកម្រិតឧត្តមសិក្សា(សាកលវិទ្យាល័យ) ជាហេតុធ្វើឲ្យការចុះឈ្មោះចូលរៀនក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈនៅមានកម្រិតទាប។ កន្លងមកគ្រឹះស្ថានសិក្សាភាគច្រើនមិនទាន់បានអនុវត្តយន្តការផ្តល់ការណែនាំឲ្យបានទូលំទូលាយដល់សិស្សឲ្យមានជម្រើសផ្សេងៗ រួមទាំងការផ្សព្វផ្សាយអំពីសារៈសំខាន់នៃការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ ទស្សនៈអវិជ្ជមានដែលមានលក្ខណៈទូទៅសម្រាប់បណ្តាប្រទេសមួយចំនួនក្នុងអាស៊ាន ត្រូវបានចាត់ទុកថាការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ជា **"ឱកាសទីពីរ"** និង **"ចំណាត់ថ្នាក់ទីពីរ"** សម្រាប់តែជនក្រីក្រ ជនងាយរងគ្រោះ និងជនបោះបង់ការសិក្សាពីប្រព័ន្ធអប់រំចំណេះទូទៅ។ ទាំងនេះក៏ជាឧបសគ្គដ៏ធំសម្រាប់ការចុះឈ្មោះចូលរៀនក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈដែលធ្វើការបណ្តុះបណ្តាលកម្លាំងពលកម្មសម្រាប់វិស័យឧស្សាហកម្មដែលមានស្រាប់និងកំពុងកើតមានថ្មីៗ។

**១.៣.៣- ថវិកាមានកម្រិតសម្រាប់ប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ**

ថវិការបស់រាជរដ្ឋាភិបាលសម្រាប់វិស័យនេះពុំទាន់បានគ្រប់គ្រាន់នៅឡើយ ដោយសារការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ត្រូវការចំណាយយ៉ាងច្រើនក្នុងការធ្វើឲ្យកម្លាំងពលកម្មមានលក្ខណសម្បត្តិគ្រប់គ្រាន់និងជំនាញច្បាស់លាស់ ដើម្បីបំពេញតម្រូវការរបស់វិស័យឧស្សាហកម្មចំពោះមុខនិងការអភិវឌ្ឍសេដ្ឋកិច្ចយូរអង្វែង ជាពិសេសកម្លាំងពលកម្មទាំងនេះមានលទ្ធភាពអាចចូលរួមប្រកួតប្រជែងជាមួយកម្លាំងពលកម្មផ្សេងទៀតក្នុងតំបន់។ លើសពីនេះការចូលរួមហិរញ្ញវត្ថុពីវិស័យឯកជនឬភាគីពាក់ព័ន្ធ គឺជាការចាំបាច់បំផុត ដើម្បីគាំទ្រដល់ការអភិវឌ្ឍវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈឲ្យមានស្ថិរភាព។

**១.៣.៤- ការទទួលស្គាល់ពុំទាន់ទូលំទូលាយចំពោះកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈឆ្លងប្រព័ន្ធ**

ទោះបីជាក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជាត្រូវបានអនុម័តរួចហើយ ក៏វានៅមានបញ្ហាមួយចំនួនរួមមាន ក- ការផ្សារភ្ជាប់រវាងកម្មវិធីសិក្សាចំណេះទូទៅនិងកម្មវិធីសិក្សាអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ នៅមានកម្រិត ខ- កង្វះការខិតខំប្រឹងប្រែងរួមគ្នានៅក្នុងការបណ្តុះបណ្តាលគ្រូបច្ចេកទេសនិងការចែករំលែកសម្ភារៈសិក្សាក្នុងចំណោមក្រសួងពាក់ព័ន្ធ គ- កម្មវិធីស្ពានចម្លងបន្តជំនាញ ព្រមទាំងការផ្តល់វិញ្ញាបនបត្រឆ្លងក្រសួង និងគ្រឹះស្ថានបណ្តុះបណ្តាលដែលពាក់ព័ន្ធនៅមិនទាន់អនុវត្តបានទូលំទូលាយ ឃ- កង្វះខាតលំហូរព័ត៌មានទីផ្សារការងារនិងព័ត៌មានអំពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ រវាងភាគីពាក់ព័ន្ធ។

**១.៣.៥- ជំនាញមូលដ្ឋាននិងជំនាញទន់នៅមានកម្រិត**

ការរៀបចំខ្លួនសម្រាប់អ្នកស្វែងរកការងារលើកដំបូងត្រូវបានចាត់ទុកថា នៅមានកម្រិតដោយសារតែពួកគេខ្វះខាតបទពិសោធមូលដ្ឋានក្នុងជីវិត និងភាពចាស់ទុំក្នុងការធ្វើការងារ កង្វះជំនាញបច្ចេកទេស ឬជំនាញសម្រាប់ធ្វើការងារ រួមទាំងមានអាកប្បកិរិយាមិនល្អ ឬកង្វះការតាំងចិត្ត។ ជាញឹកញាប់ សិស្សដែលបានបញ្ចប់ការសិក្សានៅខ្វះជំនាញជាមូលដ្ឋានដូចជាការអាន ការសរសេរ ការគិតលេខ កុំព្យូទ័រ ការប្រាស្រ័យទាក់ទងគ្នា ការធ្វើការងារជាក្រុម

ព្រមទាំងជំនាញដោះស្រាយបញ្ហា។ ជំនាញចំនួន៥ដែលចាំបាច់ត្រូវពង្រឹងឡើងវិញ ហើយត្រូវបានលើកឡើងដោយសហគ្រាសភាគច្រើន រួមមានជំនាញការងារជាក់លាក់ ទំនាក់ទំនងផ្ទាល់មាត់ ការធ្វើការងារជាក្រុម ភាសាបរទេស និងការយល់ដឹងអំពីការកសាងទំនាក់ទំនងជាមួយអតិថិជន[៥]។

**១.៣.៦- កម្រិតនៃការចូលរួមរបស់ភាគីពាក់ព័ន្ធ**

ទាំងនេះធ្វើឲ្យប៉ះពាល់ដល់គុណភាព ប្រសិទ្ធភាពនៃការចំណាយ និងភាពឆ្លើយតបរបស់វិស័យអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ ជាហេតុនាំឲ្យវិស័យនេះបន្តជួបប្រទះបញ្ហាប្រឈមមួយចំនួន រួមមានបទពិសោធជាក់ស្ដែងជាមួយឧស្សាហកម្មរបស់គ្រូបច្ចេកទេសនៅមានកម្រិត កម្មវិធីកម្មសិក្សា មិនទាន់មានគ្រប់គ្រាន់សម្រាប់សិស្ស ហើយការអនុវត្តតាមស្ដង់ដាជំនាញក៏នៅមិនទាន់បានគ្រប់ជ្រុងជ្រោយដែលជាហេតុនាំឲ្យកម្មវិធីបណ្ដុះបណ្ដាលមិនទាន់ឆ្លើយតបទៅតាមតម្រូវការទីផ្សារការងារ។

**១.៣.៧- កង្វះខាតការគាំទ្រទាំងសម្ភារៈសិក្សានិងធនធានថវិកាសម្រាប់សិក្ខាកាម សិស្ស និស្សិត**

នាពេលបច្ចុប្បន្ន បញ្ហាប្រឈមធំៗរបស់យុវជនកំពុងជួបប្រទះក្នុងការសិក្សា រួមមានកង្វះការគាំទ្រជាថវិកា ការធ្វើសេចក្ដីសម្រេចការគាំទ្រគំនិត និងកង្វះការណែនាំអំពីមុខរបរ។ លើសពីនេះ យុវជនក៏បានលើកឡើងនូវតម្រូវការដែលជាចំណុចអាទិភាពមួយចំនួន ដើម្បីពួកគេអាចបន្តការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ ដូចជាការផ្ដល់កន្លែងស្នាក់នៅ ការជួយឧបត្ថម្ភ ប្រាក់សម្រាប់អាហារ ព្រមទាំងការជួយរកការងារធ្វើបន្ទាប់ពីបញ្ចប់ការសិក្សា[៥]។

**១.៣.៨- កម្រិតនៃអភិបាលកិច្ចនិងការសម្របសម្រួលក្នុងប្រព័ន្ធអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ**

ទោះបីជាក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ត្រូវបានរាជរដ្ឋាភិបាលប្រគល់បេសកកម្មឲ្យដឹកនាំនិងគ្រប់គ្រងវិស័យអប់រំបណ្ដុះបណ្ដាលនិងវិជ្ជាជីវៈ នៅទូទាំងប្រទេសដូចបានចែងក្នុងអនុក្រឹត្យ[៦]និងសារាចរណែនាំ[៧] ប៉ុន្តែការអនុវត្តនៅមានកម្រិត ជាពិសេស ក្រសួងនិងស្ថាប័នមួយចំនួននៅពុំទាន់បានធ្វើកិច្ចសហការឲ្យស្របទៅនឹងការចាត់តាំងរបស់រាជរដ្ឋាភិបាលនៅឡើយ។ ការសម្របសម្រួលរបស់គណៈកម្មាធិការជាតិបណ្ដុះបណ្ដាល គឺមានភាពចាំបាច់ដល់ការអនុវត្តគោលនយោបាយជាតិនេះក្នុងចំណោមភាគីពាក់ព័ន្ធ។

## ២- ចក្ខុវិស័យ

គោលនយោបាយជាតិស្ដីពីការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ មានចក្ខុវិស័យលើកកម្ពស់ជីវភាពរស់នៅ សេចក្ដីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ បង្កើនបាននូវកម្លាំងពលកម្មឬធនធានមនុស្សកម្ពុជាប្រកបដោយចំណេះដឹង សមត្ថភាព ជំនាញ ឥរិយាបថការងារ សីលធម៌វិជ្ជាជីវៈ ផលិតភាពខ្ពស់ និងមានលក្ខណៈប្រកួតប្រជែងសម្រាប់ការងារពេញមួយជីវិត។

[៤] របាយការណ៍លទ្ធផលសិក្សាស្រាវជ្រាវស្ដីពីកង្វះជំនាញនិងគម្លាតជំនាញក្នុងទីផ្សារការងារនៅកម្ពុជាផ្ដោតលើភស្តុតាងការស្ទង់មតិលើតម្រូវការជំនាញរបស់និយោជក ឆ្នាំ២០១៤ របស់ទីភ្នាក់ងារជាតិមុខរបរនិងការងារ។

[៥] របាយការណ៍សិក្សាស្រាវជ្រាវស្ដីពីការស្ទាបស្ទង់មតិលើតម្រូវការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ សម្រាប់យុវជននៅខេត្តសៀមរាបក្នុងឆ្នាំ២០១៥ របស់អគ្គនាយកដ្ឋានអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈនៃក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។

[៦] អនុក្រឹត្យស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈរបស់រាជរដ្ឋាភិបាល លេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤។

[៧] សារាចរណែនាំស្ដីពីការលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈរបស់រាជរដ្ឋាភិបាល លេខ០១ សរណន ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១១។

## ៣- គោលបំណងនិងគោលដៅ

### ៣.១- គោលបំណង

ដើម្បីសម្រេចបាននូវចក្ខុវិស័យខាងលើ ចាំបាច់តម្រូវឲ្យមានការអភិវឌ្ឍជាប្រចាំបន្ថែមទៀតលើប្រព័ន្ធគ្រប់គ្រង និងលើកកម្ពស់ប្រព័ន្ធអភិវឌ្ឍជំនាញផ្អែកលើគុណភាពដែលឆ្លើយតបតាមតម្រូវការកម្លាំងពលកម្មសម្រាប់ការងារសមរម្យ ដើម្បីអភិវឌ្ឍឧស្សាហកម្មឈានទៅកកំណើនសេដ្ឋកិច្ចនិងផលិតភាពខ្ពស់។ ដូច្នេះគោលនយោបាយជាតិនេះបានកំណត់នូវគោលបំណងដូចខាងក្រោម៖

៣.១.១- ពង្រឹងគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ឲ្យស្របតាមតម្រូវការទីផ្សារការងារក្នុងនិងក្រៅប្រទេស។

៣.១.២- បង្កើនលទ្ធភាពទទួលបានការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ប្រកបដោយសមធម៌សម្រាប់បង្កើតការងារ។

៣.១.៣- លើកទឹកចិត្តភាពជាដៃគូរវាងរដ្ឋនិងឯកជន និងកៀរគរធនធានពីភាគីពាក់ព័ន្ធឲ្យចូលរួមក្នុងការអភិវឌ្ឍនិងធានានិរន្តរភាពនៃប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

៣.១.៤- លើកកម្ពស់អភិបាលកិច្ចក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

### ៣.២- គោលដៅ

ដើម្បីសម្រេចបានគោលបំណង៣.១.១. "ពង្រឹងគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ឲ្យស្របតាមតម្រូវការទីផ្សារការងារក្នុងនិងក្រៅប្រទេស" គោលនយោបាយនេះបានដាក់ចេញនូវគោលដៅដូចខាងក្រោម៖

៣.២.១.១- បន្តរៀបចំនិងអនុវត្តប្រព័ន្ធធានាគុណភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ផ្អែកលើក្របខណ្ឌគុណវុឌ្ឍជាតិកម្ពុជា។

៣.២.១.២- ពង្រឹងគុណភាពនិងគរុកោសល្យរបស់គ្រូបណ្តុះបណ្តាល ហេដ្ឋារចនាសម្ព័ន្ធ រួមទាំងធនធានមូលដ្ឋានសម្រាប់រៀននិងបង្រៀនឲ្យឆ្លើយតបតាមការអភិវឌ្ឍបច្ចេកវិទ្យាថ្មីនិងតម្រូវការទីផ្សារការងារ។

៣.២.១.៣- អភិវឌ្ឍសួនបច្ចេកទេសនិងវិជ្ជាជីវៈ នៅតាមតំបន់ឧស្សាហកម្មឬសេដ្ឋកិច្ច ដើម្បីប្រើប្រាស់ទៅតាមសក្តានុពលនូវសម្ភារៈបរិក្ខារ និងគ្រូបណ្តុះបណ្តាលប្រកបដោយសមត្ថភាពនៅតាមឧស្សាហកម្ម។

ដើម្បីសម្រេចបានគោលបំណង៣.១.២." បង្កើនលទ្ធភាពទទួលបានការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ប្រកបដោយសមធម៌សម្រាប់បង្កើតការងារ" គោលនយោបាយនេះបានដាក់ចេញនូវគោលដៅដូចខាងក្រោម៖

៣.២.២.១- បង្កើនការចុះឈ្មោះចូលរៀនក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដោយផ្តល់នូវជម្រើសផ្សេងៗដែលមានភាពបត់បែន។

៣.២.២.២- បង្កើនឱកាសដល់ប្រជាពលរដ្ឋ ដើម្បីទទួលបាននូវជំនាញសម្រាប់ជីវិតដោយយកចិត្តទុកដាក់ពិសេសលើតម្រូវការរបស់ស្ត្រី ជនងាយរងគ្រោះ យុវជនទីទ័លក្រ សិស្សដែលបានបោះបង់ ការសិក្សា ពលករចំណាកស្រុក និងជនជាតិដើមភាគតិច។

៣.២.២.៣- បង្កើនគ្រប់មធ្យោបាយនិងយន្តការផ្សេងៗ ដើម្បីពង្រីកការផ្តល់ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ផ្អែកលើក្របខណ្ឌគុណវុឌ្ឍជាតិកម្ពុជាដល់គ្រប់គ្រឹះស្ថាន និងភាគីពាក់ព័ន្ធ។

៣.២.២.៤- បង្កើនការយល់ដឹងអំពីប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ តាមរយៈការប្រឹក្សាយោបល់ ការណែនាំអំពីអាជីពការងារនិងជំនាញវិជ្ជាជីវៈ ការផ្សព្វផ្សាយរបស់គ្រឹះស្ថាននៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនិងសហគមន៍មូលដ្ឋាន។

៣.២.២.៥- បង្កើតច្រកចេញចូលតែមួយនិងផ្តល់សេវាកម្មផ្សេងៗឲ្យកាន់តែងាយស្រួលជាងមុនពាក់ព័ន្ធនឹងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

ដើម្បីសម្រេចបានគោលបំណង៣.១.៣. "លើកទឹកចិត្តភាពជាដៃគូរវាងរដ្ឋនិងឯកជន និងកៀរគរធនធានពីភាគីពាក់ព័ន្ធឲ្យចូលរួមក្នុងការអភិវឌ្ឍ និងធានានិរន្តរភាពនៃប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ" គោលនយោបាយនេះបានដាក់ចេញនូវគោលដៅដូចខាងក្រោម៖

៣.២.៣.១- ជំរុញភាពជាដៃគូរវាងរដ្ឋនិងឯកជន និងភាគីពាក់ព័ន្ធនៅក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

៣.២.៣.២- ពង្រីកភាពជាដៃគូរវាងរដ្ឋឯកជននិងភាគីពាក់ព័ន្ធក្នុងការអភិវឌ្ឍកម្មវិធីសិក្សាផ្អែកលើតម្រូវការទីផ្សារការងារ ដើម្បីពង្រឹងជំនាញឲ្យស្របនឹងបច្ចេកវិទ្យាថ្មីៗនិងមានស្រាប់។

៣.២.៣.៣- បង្កើតយន្តការសម្របសម្រួល ដើម្បីរៀបចំមូលនិធិជាតិសម្រាប់ការអភិវឌ្ឍជំនាញពីគ្រប់ភាគីពាក់ព័ន្ធ។

៣.២.៣.៤- បន្តរៀបចំគោលការណ៍បង់ថ្លៃសិក្សាសម្រាប់គ្រឹះស្ថានផ្តល់ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងផ្តល់អាហារូបករណ៍សម្រាប់សិស្ស និស្សិតក្រីក្រ ជាពិសេស ស្ត្រីនិងជនជាតិដើមភាគតិច។

ដើម្បីសម្រេចបានគោលបំណង៣.១.៤. "លើកកម្ពស់អភិបាលកិច្ចក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ" គោលនយោបាយនេះបានដាក់ចេញនូវគោលដៅដូចខាងក្រោម៖

៣.២.៤.១- ពង្រឹងយន្តការក្របខណ្ឌគតិយុត្តសម្រាប់ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីភ្ជាប់ការបណ្តុះបណ្តាលជំនាញទៅនឹងតម្រូវការទីផ្សារការងារ។

៣.២.៤.២- រៀបចំយន្តការផ្តល់មូលនិធិផ្អែកលើលទ្ធផលការងារ សម្រាប់ប្រតិបត្តិការរបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

៣.២.៤.៣- បន្តកែលម្អប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងប្រព័ន្ធព័ត៌មាន ទីផ្សារការងារ ព្រមទាំងពង្រឹងការវិភាគ ព្យាករណ៍ទីផ្សារការងារ និងការស្ទង់មតិលើតម្រូវការជំនាញ។

## ៤- យុទ្ធសាស្ត្រ

ដើម្បីសម្រេចបាននូវចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើ យុទ្ធសាស្ត្រគន្លឹះរបស់រាជរដ្ឋាភិបាលផ្តោតជាសំខាន់លើការរៀបចំនិងអនុវត្តនូវក្របខណ្ឌគោលនយោបាយមួយច្បាស់លាស់ដែលប្រទាក់ក្រឡានិងបំពេញគ្នាទៅវិញទៅមករវាងស្ថាប័នពាក់ព័ន្ធទាំងអស់ ដើម្បីធានានូវប្រសិទ្ធភាពនៃការអនុវត្ត "គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ"។ ដូចបានរៀបរាប់ខាងលើ ក្របខណ្ឌគោលនយោបាយនេះនឹងផ្តោតលើសសរស្តម្ភចំនួនបួន៖ **ទី១.** ពង្រឹងគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ **ទី២.** បង្កើនលទ្ធភាពទទួលបានការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ **ទី៣.** លើកទឹកចិត្តភាពជាដៃគូរវាងរដ្ឋនិងឯកជន និង**ទី៤.** អភិបាលកិច្ចនៃប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

លើសពីនេះ គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការកសាងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈមួយមានភាពបត់បែន ដែលឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារទាំងក្នុងនិងក្រៅប្រទេស ព្រមទាំងផ្តល់លទ្ធភាពដល់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបបន្តការសិក្សានិងអភិវឌ្ឍជំនាញរបស់ពួកគេពេញមួយជីវិត។ ប្រព័ន្ធនេះនឹងគាំទ្រការកែលម្អក្នុងការធ្វើពិពិធកម្មផលិតភាពក្នុងវិស័យឧស្សាហកម្ម និងបង្កើនសមត្ថភាពកម្លាំងពលកម្មឲ្យឆ្លើយតបនឹងបច្ចេកវិទ្យាថ្មីៗ ព្រមទាំងសេវាកម្មនិងផលិតផលប្រសើរជាងមុន។

អាស្រ័យហេតុនេះគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ បានដាក់ចេញនូវយុទ្ធសាស្ត្រមួយចំនួនដូចខាងក្រោម ដើម្បីបំពេញនូវចំណុចខ្វះខាតពាក់ព័ន្ធនឹងការធានាគុណភាព ការគ្រប់គ្រង ការផ្សព្វផ្សាយប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ក្នុងការសម្រេចឲ្យបាននូវសកម្មភាពគាំទ្រក្នុងការបង្កើនឱកាសការងារសមរម្យតាមវិស័យក្នុងទីតាំងភូមិសាស្ត្រផ្សេងៗ ឈានទៅរកការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ចជាតិ។

## ៤.១- យុទ្ធសាស្ត្រទី១. ពង្រឹងគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ឱ្យស្រប តាមតម្រូវការទីផ្សារការងារក្នុងនិងក្រៅប្រទេស

គោលបំណង គឺសំដៅលើការកែលម្អគុណភាពគ្រប់ទិដ្ឋភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ រួមទាំងការរៀបចំបទដ្ឋានគតិយុត្តនិងក្របខណ្ឌច្បាប់ផ្សេងៗ។ លើសពីនេះ ការកែលម្អនិងពង្រឹងប្រព័ន្ធធានាគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ គឺដើម្បីធានាឲ្យបាននូវសង្គតិភាព សេវាកម្មប្រកបដោយគុណភាពដែលមានទំនុកចិត្ត សម្ភារៈបរិក្ខារ វិធីសាស្ត្របណ្តុះបណ្តាលសមស្របកម្មវិធីសិក្សា និងកម្មវិធីបណ្តុះបណ្តាលផ្សារភ្ជាប់នឹងការងារ ប្រព័ន្ធវាយតម្លៃជំនាញផ្អែកលើតម្រូវការអាជីវកម្មនិងឧស្សាហកម្ម ការផ្តល់វិញ្ញាបនបត្រដល់កម្លាំងពលកម្មថ្មី និងមានស្រាប់តាមរយៈការទទួលស្គាល់សមត្ថភាព ការគាំទ្រការអភិវឌ្ឍសមត្ថភាពបុគ្គលិក ព្រមទាំងការរៀបចំការបណ្តុះបណ្តាលក្នុងកិច្ចសហការជាមួយសហគ្រិនឲ្យឆ្លើយតបនឹងតម្រូវការការងារជាក់ស្តែង។ គុណភាពនៃកម្មវិធីបណ្តុះបណ្តាលនឹងត្រូវបានគាំទ្រដោយគ្រឹះស្ថានបណ្តុះបណ្តាល និងមានការទទួលស្គាល់ទាំងនៅថ្នាក់ជាតិនិងថ្នាក់តំបន់។ ការចូលរួមពីផ្នែកឧស្សាហកម្ម សហគមន៍ និងភាគីពាក់ព័ន្ធផ្សេងៗនឹងពង្រឹងលទ្ធផលនៃការបណ្តុះបណ្តាលទាក់ទងនឹងការងារ ព្រមទាំងបង្កើនភាពប្រកួតប្រជែងក្នុងការទាក់ទាញឧស្សាហកម្មថ្មីៗ និងចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

### ៤.១.១- បន្តរៀបចំនិងអនុវត្តប្រព័ន្ធធានាគុណភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ផ្អែកលើក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា

១- រៀបចំលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីគាំទ្រក្នុងការត្រួតពិនិត្យ តាមដាន និងវាយតម្លៃសម្រាប់ការអនុវត្តក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ស្របតាមការអភិវឌ្ឍវិស័យឧស្សាហកម្ម។

២- ធ្វើការសម្របសម្រួលឲ្យមានការទទួលស្គាល់អំពីកម្រិតគុណវុឌ្ឍិរវាងក្របខណ្ឌជាតិកម្ពុជា ជាមួយក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន ក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

៣- ពង្រឹងការអនុវត្តធានាគុណភាព ត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដោយប្រើប្រាស់លក្ខណវិនិច្ឆ័យដែលបានកំណត់ស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ដើម្បីជំរុញការប្រកួតប្រជែងគុណភាពនិងសេវា។

៤- អភិវឌ្ឍនិងអនុវត្តផែនការសកម្មភាព គោលការណ៍ណែនាំ និងនីតិវិធីនៃលក្ខណវិនិច្ឆ័យសម្រាប់ទទួលស្គាល់វគ្គ កម្មវិធីបណ្តុះបណ្តាល និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

៥- អភិវឌ្ឍនិងអនុវត្តការវាយតម្លៃផ្អែកលើសមត្ថភាពឬលទ្ធផលសិក្សា ការធ្វើតេស្តសមត្ថភាព ការទទួលស្គាល់ការសិក្សាពីមុន និងការទទួលស្គាល់សមត្ថភាពនាពេលបច្ចុប្បន្ន ព្រមទាំងការផ្តល់លិខិតបញ្ជាក់វិញ្ញាបនបត្រ សញ្ញាបត្រ និងអាជ្ញាបណ្ណ។

៦- រៀបចំបទដ្ឋានគតិយុត្តស្តីពីការផ្តល់វិញ្ញាបនបត្រដែលចែងពីនីតិវិធីក្នុងការទទួលស្គាល់សមត្ថភាព ស្របតាមកម្រិតនៃក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា។

៧- បង្កើតមជ្ឈមណ្ឌលថ្នាក់ជាតិសម្រាប់ធ្វើតេស្តជំនាញបញ្ជាក់សមត្ថភាព ដើម្បីគាំទ្រដល់មុខរបរនិងជំនាញអាទិភាព។

៨- រៀបចំក្របខណ្ឌនិងស្តង់ដាសម្រាប់ការអប់រំចំណេះទូទៅនិងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីផ្តល់ភាពងាយស្រួលក្នុងការផ្ទេរពីគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ទៅគ្រឹះស្ថានឧត្តមសិក្សា។

៩- កំណត់យកអង្គភាពក្នុងក្រសួងឬគ្រឹះស្ថានផ្តល់ការបណ្តុះបណ្តាល ដើម្បីធ្វើជាអង្គភាពបង្គោលក្នុងការសម្របសម្រួលអនុវត្តនិងថែរក្សានូវប្រព័ន្ធធានាគុណភាពសម្រាប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ទាំងស្ថាប័នសាធារណៈ ឯកជន និងអង្គការមិនមែនរដ្ឋាភិបាល។

១០- បណ្តុះបណ្តាលដល់មន្ត្រី បុគ្គលិករបស់គ្រឹះស្ថានសិក្សាអំពីនីតិវិធីស្វ័យវាយតម្លៃនិងតម្រូវការនានា ដើម្បីទទួលបានការទទួលស្គាល់គុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

១១- រៀបចំវាយតម្លៃគុណភាពជំនាញ តាមរយៈការប្រើប្រាស់កម្រងសំណួរលើបណ្តាញអ៊ីនធឺណែតដល់ភាគីពាក់ព័ន្ធ រួមទាំងសិស្សដែលបានបញ្ចប់ការសិក្សាឲ្យបានទៀងទាត់។

### ៤.១.២- ពង្រឹងគុណភាពនិងគរុកោសល្យរបស់គ្រូបណ្តុះបណ្តាល ហេដ្ឋារចនាសម្ព័ន្ធរួមទាំងធនធានមូលដ្ឋានសម្រាប់រៀននិងបង្រៀនឲ្យឆ្លើយតបតាមការអភិវឌ្ឍបច្ចេកវិទ្យាថ្មី និងតម្រូវការរបស់ទីផ្សារការងារ

១- រៀបចំចងក្រងលិខិតបទដ្ឋានគតិយុត្តដែលតម្រូវឲ្យគ្រូបច្ចេកទេសឆ្លងកាត់វគ្គបណ្តុះបណ្តាលស្តីពីគរុកោសល្យ ព្រមទាំងបង្កើនជំនាញឧស្សាហកម្មជាប្រចាំ។

២- លើកកម្ពស់សមត្ថភាពនិងគុណវុឌ្ឍិគ្រូបច្ចេកទេស ជាពិសេស ស្ត្រីលើជំនាញនិងគរុកោសល្យដើម្បីទទួលបាននូវបទពិសោធថ្មីៗពីផ្នែកឧស្សាហកម្មទាំងក្នុងនិងក្រៅប្រទេស។

៣- បណ្តុះបណ្តាលគ្រូបច្ចេកទេសអំពីស្តង់ដាសមត្ថភាព ការវាយតម្លៃផ្អែកលើសមត្ថភាព ការរៀបចំឯកសារ កញ្ចប់សិក្សា និងសម្ភារៈវាយតម្លៃដែលជាតម្រូវការរបស់ស្ថាប័នទទួលបន្ទុក។

៤- រៀបចំផែនការបង្កើនសមត្ថភាពវិជ្ជាជីវៈប្រចាំឆ្នាំតាមកម្រិតសម្រាប់គ្រូបច្ចេកទេសនៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

៥- កែលម្អហេដ្ឋារចនាសម្ព័ន្ធនិងធនធានមូលដ្ឋាន រួមមានសម្ភារៈឧបទេស រោងជាង ឯកសារ បណ្ណាល័យដោយមានភ្ជាប់សេវាអ៊ីនធឺណែតនៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ឲ្យបានគ្រប់គ្រាន់ដោយផ្អែកលើតម្រូវការបណ្តុះបណ្តាលនិងការរីកចម្រើនរបស់ឧស្សាហកម្ម។

៦- ពិនិត្យលទ្ធភាពប្រើប្រាស់ធនធានដែលអាចប្រើប្រាស់រួមគ្នាបាន ក្នុងចំណោមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីធ្វើឲ្យសិស្សទទួលបានការអប់រំមូលដ្ឋាននិងជំនាញបញ្ចូលគ្នាដែលជាផ្នែកមួយនៃកម្មវិធីសិក្សា។

៧- ពង្រឹងគុណភាពគ្រឹះស្ថានបណ្តុះបណ្តាលគរុនិស្សិតដោយផ្សារភ្ជាប់ទ្រឹស្តីទៅនឹងឱកាសធ្វើកម្មសិក្សានៅក្នុងឧស្សាហកម្ម។

៨- លើកកម្ពស់សមភាពយេនឌ័រ តាមរយៈការជំរុញលើកទឹកចិត្តស្ត្រីឲ្យធ្វើជាគ្រូនិងអ្នកគ្រប់គ្រងនៅក្នុងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ទៅតាមចំនួនកំណត់អតិបរមា។

៩- កំណត់វិធានការលើកទឹកចិត្តគ្រូដែលត្រូវបំពេញការងារតាមខេត្តឲ្យបំពេញតួនាទីទៅតាមការចាត់តាំងប្រកបដោយប្រសិទ្ធភាព។

១០- រៀបចំវិធានការទាក់ទាញអ្នកវិទ្យាសាស្ត្រ អ្នកបច្ចេកទេសឆ្នើមៗ និងសិស្សពូកែៗឲ្យងាកមករៀនឬបម្រើការងារក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

១១- ធានាថាគ្រូបណ្តុះបណ្តាលជំនាញនិងសិស្សទទួលបានការបណ្តុះបណ្តាលអំពីបរិស្ថាននិងផលប៉ះពាល់នៃការងារទៅនឹងបរិស្ថាន រួមទាំងជំនាញបៃតង(green skills)។

### ៤.១.៣- អភិវឌ្ឍសួនបច្ចេកទេសនិងវិជ្ជាជីវៈ នៅតាមតំបន់ឧស្សាហកម្មឬសេដ្ឋកិច្ច ដើម្បីប្រើប្រាស់ទៅតាមសក្តានុពលនូវសម្ភារៈបរិក្ខារនិងគ្រូបណ្តុះបណ្តាលប្រកបដោយសមត្ថភាពនៅតាមឧស្សាហកម្ម

១- សិក្សានិងបង្កើតសួនបច្ចេកទេសនិងវិជ្ជាជីវៈ នៅតាមតំបន់ឧស្សាហកម្មនិងសេដ្ឋកិច្ចសំខាន់ៗ។

២- បង្កើតមជ្ឈមណ្ឌលឧត្តមភាព ដើម្បីពង្រឹងគុណភាពបណ្តុះបណ្តាល ស្របតាមតម្រូវការទីផ្សារការងារដោយមានការចូលរួមពីភាគីពាក់ព័ន្ធ។

៣- បង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ ដើម្បីសិក្សាលើមុខជំនាញថ្មីៗ និងបំពេញតម្រូវការទីផ្សារការងារក្នុងប្រទេសនិងតំបន់។

៤- បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលធនធានមនុស្សសំដៅបង្កើននិងពង្រឹងសមត្ថភាពមន្ត្រីជំនាញ។

## ៤.២- យុទ្ធសាស្ត្រទី២. បង្កើនលទ្ធភាពទទួលបានការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈប្រកបដោយសមធម៌សម្រាប់បង្កើតការងារ

គោលបំណង គឺដើម្បីបង្កើនការចុះឈ្មោះចូលរៀនរបស់សិក្ខាកាម សិស្ស និស្សិតទៅក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈឲ្យបានទូលំទូលាយ ព្រមទាំងធានាបានថាប្រជាពលរដ្ឋទាំងអស់មានឱកាសទទួលបានការបណ្តុះបណ្តាលប្រកបដោយសមធម៌។ ប្រព័ន្ធនេះគឺជាមូលដ្ឋាននៃការរៀនសូត្រពេញមួយជីវិតនិងធានាបន្តការអភិវឌ្ឍជំនាញដែលជាតម្រូវការសេដ្ឋកិច្ច ហើយវាចាំបាច់ត្រូវបើកទូលាយសម្រាប់ប្រជាពលរដ្ឋគ្រប់រូប ជាពិសេស ស្ត្រី ជនងាយរងគ្រោះ និងក្រុមជនជាតិដើមភាគតិច ដើម្បីស្វែងរកការងារសមរម្យដោយប្រើប្រាស់ជំនាញរបស់ពួកគេ។

### ៤.២.១- បង្កើនការចុះឈ្មោះចូលរៀនក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដោយផ្តល់នូវជម្រើសផ្សេងៗដែលមានភាពបត់បែន

១- បង្កើនលទ្ធភាពទទួលបានការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ តាមរយៈការរៀបចំនិងអនុវត្តការទទួលស្គាល់ការសិក្សាដែលមានពីមុន និងការទទួលស្គាល់សមត្ថភាពនាពេលបច្ចុប្បន្ន ស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា និងធ្វើការវាយតម្លៃ តាមរយៈប្រព័ន្ធវាយតម្លៃជំនាញ។

២- ពង្រីកកម្មវិធីផ្សព្វផ្សាយអំពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ នៅកន្លែងធ្វើការដើម្បីផ្តល់ព័ត៌មាន អំពីផលប្រយោជន៍សេដ្ឋកិច្ចដែលនឹងទទួលបានពីការពង្រឹងជំនាញបន្ថែមទៀត។

៣- ពង្រីកកម្មវិធីបណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់និងកម្មវិធីស្ពានចម្លងបន្តជំនាញ ដើម្បីផ្តល់លទ្ធភាពដល់សិស្សដែលបានបោះបង់ការសិក្សា និងកម្លាំងពលកម្មដែលកំពុងធ្វើការឲ្យបន្តការរៀនសូត្រក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

៤- បង្កើនអាហារូបករណ៍សម្រាប់ក្រុមសិស្សគោលដៅ ជាពិសេស សម្រាប់ស្ត្រី ដើម្បីលើកទឹកចិត្តពួកគេឱ្យបន្តការសិក្សាក្នុងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ រួមទាំងការផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់កម្មវិធីស្ពានចម្លងបន្តជំនាញដែលភ្ជាប់នឹងក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជាកម្រិតទី២។

៥- ពង្រីកកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ រយៈពេលវែងដល់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ នៅតាមបណ្តាខេត្ត រាជធានីដែលមិនទាន់មាន។

៦- ជំរុញនិងលើកទឹកចិត្តដល់សិស្សដែលទទួលបានការបណ្តុះបណ្តាលជំនាញឲ្យមានលទ្ធភាពអាចបង្កើតមុខរបរដោយខ្លួនឯង តាមរយៈការណែនាំឲ្យមានការយល់ដឹងពីកម្មវិធីឥណទានឬការផ្តល់ឥណទានខ្នាតតូច។

៧- រៀបចំនិងអនុវត្តកម្មវិធីបណ្តុះបណ្តាលធនធានមនុស្សសំដៅពលករជំនាញ ដើម្បីធ្វើការចល័តក្នុងតំបន់។

### ៤.២.២- បង្កើនឱកាសដល់ប្រជាពលរដ្ឋ ដើម្បីទទួលបាននូវជំនាញសម្រាប់ជីវិតដោយយកចិត្តទុកដាក់ពិសេសដល់តម្រូវការរបស់ស្ត្រី ជនងាយរងគ្រោះ យុវជនទីទ័លក្រ សិស្សដែលបានបោះបង់ការសិក្សា ពលករចំណាកស្រុក និងជនជាតិដើមភាគតិច

១- ផ្តល់អាទិភាពចំពោះស្ត្រី ក្រុមជនងាយរងគ្រោះ យុវជនទីទ័លក្រ សិស្សដែលបានបោះបង់ការសិក្សា ក្រុមជនជាតិដើមភាគតិច ពលករចំណាកស្រុក និងអ្នកគ្មានការងារធ្វើឲ្យចូលរៀនក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ តាមរយៈការផ្តល់អាហារូបករណ៍ ប្រាក់ឧបត្ថម្ភ និងអន្តេវាសិកដ្ឋានឲ្យបានគ្រប់គ្រាន់។

២- បង្កើនលទ្ធភាពទទួលបានជំនាញនិងវិញ្ញាបនបត្របញ្ជាក់ ជាពិសេស ពលករចំណាកស្រុកដែលទទួលបានប្រាក់កម្រៃទាប។

៣- លើកកម្ពស់ការយល់ដឹងអំពីយេនឌ័រនិងអនុវត្តវិធានការសមភាពនិងសមធម៌យេនឌ័រនៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ព្រមទាំងភាគីពាក់ព័ន្ធ។

### ៤.២.៣- បង្កើនគ្រប់មធ្យោបាយនិងយន្តការផ្សេងៗ ដើម្បីពង្រីកការផ្តល់ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ផ្អែកលើក្របខណ្ឌគុណវុឌ្ឍជាតិកម្ពុជាដល់គ្រប់គ្រឹះស្ថាននិងភាគីពាក់ព័ន្ធ

១- រៀបចំកម្មវិធីសិក្សាពីចម្ងាយ កម្មវិធីសិក្សាបន្ត ការបណ្តុះបណ្តាលចល័ត និងការបណ្តុះបណ្តាលរយៈពេលខ្លីនៅតាមសហគមន៍ គ្រឹះស្ថានបណ្តុះបណ្តាល សហគ្រាស ឧស្សាហកម្ម ក្រុមហ៊ុន រោងចក្រ ដើម្បីពង្រឹងលទ្ធភាពទទួលបានការបណ្តុះបណ្តាល ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការជំនាញ។

២- គាំទ្រគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ព្រមទាំងភាគីពាក់ព័ន្ធ ក្នុងការពង្រីកការបណ្តុះបណ្តាលកម្លាំងពលកម្មដោយប្រើប្រាស់ស្តង់ដាជំនាញដែលអនុម័តរួច និងផ្សារភ្ជាប់ទៅនឹងការវាយតម្លៃនៅតាមមជ្ឈមណ្ឌលធ្វើតេស្តថ្នាក់ជាតិ។

៣- បន្តអនុវត្តយន្តការប្រកួតប្រជែងជំនាញថ្នាក់ជាតិនិងថ្នាក់តំបន់លើបច្ចេកវិទ្យាគំនិតផ្តួចផ្តើមថ្មីៗក្នុងចំណោមសិស្ស និស្សិត អ្នកបច្ចេកទេស វិស្វករ គ្រូបច្ចេកទេស និងសហគ្រិនវ័យក្មេងឲ្យបានទូលំទូលាយ។

### ៤.២.៤- បង្កើនការយល់ដឹងអំពីប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ តាមរយៈការប្រឹក្សាយោបល់ ការណែនាំអំពីអាជីពការងារនិងជំនាញវិជ្ជាជីវៈ ការផ្សព្វផ្សាយរបស់គ្រឹះស្ថាននៅតាមសហគមន៍និងថ្នាក់ខេត្ត។

១- បង្កើនការផ្សព្វផ្សាយតាមមធ្យោបាយផ្សេងៗ ជាពិសេស ការផ្សព្វផ្សាយតាមបណ្តាញសង្គមឲ្យបានគ្រប់គ្រាន់ដើម្បីលើកកម្ពស់ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

២- ពង្រីកសមត្ថភាពនិងលទ្ធភាពព្រមទាំងថវិកាផ្សព្វផ្សាយឲ្យបានគ្រប់គ្រាន់ ដល់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ព្រមទាំងភាគីពាក់ព័ន្ធ ដើម្បីផ្សព្វផ្សាយការបណ្តុះបណ្តាលជំនាញនៅទូទាំងប្រទេស។

៣- រៀបចំយុទ្ធសាស្ត្រទីផ្សារនិងផ្សព្វផ្សាយអំពីជំនាញនៅតាមភូមិ ឃុំ សង្កាត់ សហគមន៍ ដើម្បីទាក់ទាញសិក្ខាកាម សិស្ស និស្សិតបោះបង់ការសិក្សា ជនក្រីក្រ ជនងាយរងគ្រោះ **ជនជាតិភាគតិច** ជាពិសេសស្ត្រីនិងជនជាតិដើមភាគតិចឲ្យចូលមកសិក្សាក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

៤- បង្កើនការផ្សព្វផ្សាយព័ត៌មានស្តីពីវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងការតម្រង់ទិសវិជ្ជាជីវៈ ដល់សិស្សានុសិស្សនៅតាមសាលាមធ្យមសិក្សាចំណេះទូទៅទូទាំងរាជធានី ខេត្ត។

៥- រៀបចំវេទិកាផ្សព្វផ្សាយនិងពិព័រណ៌ស្នាដៃសិស្ស និស្សិតក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

#### ៤.២.៥- បង្កើតច្រកចេញចូលតែមួយនិងផ្តល់សេវាកម្មផ្សេងៗឲ្យកាន់តែងាយស្រួលជាងមុនពាក់ព័ន្ធនឹងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ

១- រៀបចំឲ្យមាន "ផ្នែកច្រកចេញចូលតែមួយ" នៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីផ្តល់ ព័ត៌មានអំពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ រួមមានកម្មវិធីបណ្តុះបណ្តាលជំនាញរយៈពេលខ្លីនិងវែង កម្មវិធីជំនាញថ្មីៗ ការផ្តល់អាហារូបករណ៍ ការហ្វឹកហ្វឺនកូនជាង ការចុះធ្វើកម្មសិក្សា ឱកាសការងារនិងមីក្រូហិរញ្ញវត្ថុ។

២- រៀបចំឲ្យមានការសិក្សាស្រាវជ្រាវបង្កើតគំនិតច្នៃប្រឌិតថ្មីៗ ការផ្តល់សេវាកម្មទាក់ទងនឹងបច្ចេកវិទ្យាដែលជាតម្រូវការទីផ្សារ ដើម្បីផ្តល់ព័ត៌មានអំពីអាជីពឲ្យបានកាន់តែប្រសើរសម្រាប់សិស្សនិងកម្លាំងពលកម្ម។

៣- បន្តពង្រីក "មជ្ឈមណ្ឌលការងារ" នៅតាមតំបន់ឧស្សាហកម្មឬតំបន់សេដ្ឋកិច្ចផ្សេងៗទៀត ព្រមទាំងពង្រឹងការប្រឹក្សាយោបល់ អំពីអាជីពការងារនិងជំនាញវិជ្ជាជីវៈ ដើម្បីផ្តល់ជំបូន្មានដ៏មានប្រសិទ្ធភាពសម្រាប់ប្រជាពលរដ្ឋគ្រប់រូប។

### ៤.៣- យុទ្ធសាស្ត្រទី៣. លើកទឹកចិត្តភាពជាដៃគូរវាងរដ្ឋនិងឯកជន និងកៀរគរធនធានពីភាគីពាក់ព័ន្ធឲ្យចូលរួមក្នុងការអភិវឌ្ឍនិងធានានិរន្តរភាពនៃប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ

ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ចាំបាច់ត្រូវមានកិច្ចសហការជាដៃគូជាមួយភាគីពាក់ព័ន្ធឲ្យចូលរួមចំណែកក្នុងការរៀបចំនិងអភិវឌ្ឍប្រព័ន្ធនេះឲ្យកាន់តែប្រសើរឡើង និងស្របទៅតាមតម្រូវការទីផ្សារការងារជាក់ស្តែង។ លើសពីនេះ រាជរដ្ឋាភិបាលតែងតែគាំទ្រដល់យន្តការផ្សេងទៀត រួមមានការរៀបចំគោលនយោបាយបង់ថ្លៃសិក្សា ការលើកកម្ពស់ភាពជាដៃគូរវាងរដ្ឋនិងឯកជន ដើម្បីអភិវឌ្ឍនិងបន្តនិរន្តរភាពនៃដំណើរការរបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈផងដែរ។

#### ៤.៣.១- ជំរុញភាពជាដៃគូរវាងរដ្ឋ ឯកជន និងភាគីពាក់ព័ន្ធនៅក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ

១- ជំរុញនិងលើកកម្ពស់ការអនុវត្តយន្តការភាពជាដៃគូរវាងរដ្ឋ ឯកជន និងភាគីពាក់ព័ន្ធ ដើម្បីធានាថាកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ។

២- សហការជាមួយនិយោជកក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីលើកទឹកចិត្តនិយោជក ក្នុងការផ្តល់អាទិភាពដល់អ្នកដាក់ពាក្យចូលបម្រើការងារដែលមានសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ស្របតាមក្របខណ្ឌគុណវុឌ្ឍជាតិកម្ពុជា។

៣- រៀបចំទម្រង់ផ្សេងៗនៃភាពជាដៃគូរវាងរដ្ឋ ឯកជន និងភាគីពាក់ព័ន្ធដែលគ្របដណ្ដប់លើសហគ្រាសខ្នាតតូចនិងមធ្យម វិស័យឧស្សាហកម្ម និងវិស័យផ្សេងទៀត។

៤- រៀបចំកម្មវិធីភាពជាដៃគូរវាងរដ្ឋ ឯកជន និងភាគីពាក់ព័ន្ធ ដើម្បីទាក់ទាញការចូលរួមប្រកួតប្រជែងពីវិស័យឯកជន ព្រមទាំងគ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ ក្នុងការបង្កើនគុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ។

៥- បន្តជំរុញគ្រប់គ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ ឲ្យមកចុះបញ្ជីនៅក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈឬនៅមន្ទីរការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈរាជធានី ខេត្ត ស្របតាមកម្រិតសិក្សានីមួយៗដែលបានស្នើសុំ ដោយរាប់បញ្ចូលទាំងគ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈដែលមានច្បាប់អនុញ្ញាតពីក្រសួងឬស្ថាប័នផ្សេង ដើម្បីងាយស្រួលក្នុងការប្រមូលស្ថិតិ ការត្រួតពិនិត្យ និងការអនុវត្តតាមបទដ្ឋានក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ស្តង់ដាជាតិសមត្ថភាព ព្រមទាំងការប្រើប្រាស់ប្រព័ន្ធធ្វើតេស្តជំនាញថ្នាក់ជាតិ។

### ៤.៣.២- ពង្រីកភាពជាដៃគូរវាងរដ្ឋ ឯកជន និងភាគីពាក់ព័ន្ធក្នុងការអភិវឌ្ឍកម្មវិធីសិក្សាផ្អែកលើតម្រូវការទីផ្សារការងារ ដើម្បីពង្រឹងជំនាញឲ្យស្របនឹងបច្ចេកវិទ្យាដែលមានស្រាប់ និងថ្មីៗ

១- បន្តអភិវឌ្ឍកម្មវិធីសិក្សាគ្រប់កម្រិតឲ្យស្របទៅតាមទីផ្សារការងារនិងបច្ចេកវិទ្យាថ្មីៗដោយមានការចូលរួមពីស្ថាប័នឯកជននិងភាគីពាក់ព័ន្ធ។

២- បន្តបង្កើតក្រុមប្រឹក្សាអភិវឌ្ឍន៍ជំនាញតាមវិស័យ ដើម្បីផ្តល់ការប្រឹក្សាយោបល់និងតម្រង់ទិសក្នុងការអភិវឌ្ឍសមត្ថភាពជំនាញនិងប្រសិទ្ធភាពនៃប្រព័ន្ធអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ។

៣- បន្តអភិវឌ្ឍស្តង់ដាជាតិសមត្ថភាព កម្មវិធីសិក្សាផ្អែកលើសមត្ថភាព និងកញ្ចប់ធ្វើតេស្តបញ្ជាក់សមត្ថភាពសម្រាប់គ្រប់វិស័យអាទិភាព។

៤- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីសិក្សាផ្អែកលើស្តង់ដាជាតិសមត្ថភាពលើគ្រប់វិស័យ។

៥- ធានាថាគ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ បានបញ្ចូលទស្សនាទានសហគ្រិនភាពក្នុងកម្មវិធីបណ្ដុះបណ្ដាល ដើម្បីគាំទ្រក្នុងការប្រកបមុខរបរដោយខ្លួនឯង។

៦- ពិនិត្យនិងកែសម្រួលច្បាប់ពាក់ព័ន្ធនឹងការហ្វឹកហ្វឺនកូនជាង ឲ្យស្របតាមតម្រូវការនៃការរីកចម្រើនសេដ្ឋកិច្ច។

៧- សម្របសម្រួលនិងសហការរវាងគ្រឹះស្ថានបណ្ដុះបណ្ដាលជាមួយឧស្សាហកម្ម ដើម្បីពង្រឹងគុណភាពនិងអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង ទស្សនកិច្ចសិក្សា កម្មវិធីកម្មសិក្សា និងការបណ្ដុះបណ្ដាលនៅនឹងកន្លែងធ្វើការ។

៨- បញ្ចូលជំនាញទន់ក្នុងកម្មវិធីអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ តាមរយៈការផ្តល់នូវជំនាញដែលអាចផ្ទេរបានសម្រាប់គាំទ្រដល់ការធ្វើការងារនិងការសិក្សាពេញមួយជីវិត ព្រមទាំងជួយដល់សិស្សក្នុងការត្រៀមខ្លួនចូលក្នុងទីផ្សារការងារ។

៩- បញ្ចូលសកម្មភាពអប់រំកាយ កីឡា សិល្បៈ និងវប្បធម៌ទៅក្នុងកម្មវិធីសិក្សាព្រមទាំងកសាងហេដ្ឋារចនាសម្ព័ន្ធដើម្បីគាំទ្រសកម្មភាពទាំងនេះនៅតាមគ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ ក្នុងគោលបំណងពង្រឹងកាយសម្បទា ការយល់ដឹងពីសិល្បៈ វប្បធម៌បានច្បាស់លាស់ក្នុងដំណាក់កាលនៃនិន្នាការសកលភាវូបនីយកម្មនិងវប្បធម៌ឆ្លងកាត់ ដើម្បីរក្សាបាននូវតម្លៃនៃអត្តសញ្ញាណជាតិ។

៤.៣.៣- បង្កើតយន្តការសម្របសម្រួល ដើម្បីរៀបចំមូលនិធិជាតិសម្រាប់ការអភិវឌ្ឍជំនាញពីគ្រប់ភាគីពាក់ព័ន្ធ

១- រៀបចំគោលនយោបាយអភិវឌ្ឍន៍ជំនាញដែលលើកទឹកចិត្តវិស័យឯកជន ព្រមទាំងភាគីពាក់ព័ន្ធឲ្យចូលរួមអភិវឌ្ឍវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ តាមរយៈការចូលរួមផ្តល់ប្រឹក្សាយោបល់ការបណ្តុះបណ្តាលជំនាញ ការចូលរួមវិភាគទានហិរញ្ញវត្ថុ ជាតុចូលក្នុងការអភិវឌ្ឍកម្មវិធីសិក្សា និងការបង្កើនឱកាសដល់សិក្ខាកាម សិស្ស និស្សិតអាចធ្វើកម្មសិក្សានៅតាមបណ្តារោងចក្រ សហគ្រាស គ្រឹះស្ថានពាក់ព័ន្ធ។

២- រៀបចំមូលនិធិជាតិសម្រាប់ការអភិវឌ្ឍជំនាញ ដើម្បីគាំទ្រក្នុងការពង្រឹងជំនាញកម្លាំងពលកម្មផ្អែកលើតម្រូវការទីផ្សារការងារ។

៣- កំណត់គោលដៅមូលនិធិជាតិអភិវឌ្ឍជំនាញឬប្រភពមូលនិធិផ្សេងៗ ដើម្បីគាំទ្រការបណ្តុះបណ្តាលកម្លាំងពលកម្មដែលដឹកនាំដោយវិស័យឧស្សាហកម្មពាក់ព័ន្ធ ដើម្បីបំពេញតម្រូវការជំនាញកម្រិតខ្ពស់ ឬការផ្លាស់ប្តូររបស់បច្ចេកវិទ្យាថ្មីៗ។

៤.៣.៤- បន្តរៀបចំគោលការណ៍បង់ថ្លៃសិក្សាសម្រាប់គ្រឹះស្ថានផ្តល់ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងផ្តល់អាហារូបករណ៍សម្រាប់សិក្ខាកាម សិស្ស និស្សិតក្រីក្រ ជាពិសេសស្ត្រី និងជនជាតិដើមភាគតិច

១- បន្តជំរុញគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ទាំងរដ្ឋ ទាំងឯកជន ដើម្បីរៀបចំការបង់ថ្លៃសម្រាប់ការបណ្តុះបណ្តាលជំនាញដែលស្របទៅនឹងស្តង់ដាជំនាញជាតិ យោងទៅតាមក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា។

២- ជំរុញឲ្យគ្រឹះស្ថានប្រើប្រាស់មួយភាគនៃប្រាក់ចំណូលជាកម្មវិធីអាហារូបករណ៍ដល់សិស្សក្រីក្រដែលបានកំណត់អត្តសញ្ញាណដោយក្រសួងនិងស្ថាប័នពាក់ព័ន្ធ។

៣- រៀបចំយន្តការសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ ដើម្បីផ្តល់ប្រាក់កម្ចីដល់សិស្ស និស្សិត អាចបន្តការសិក្សាក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

៤- ជំរុញគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ក្នុងការរៀបចំកិច្ចព្រមព្រៀងជាមួយសហគ្រាស ដើម្បីផ្តល់កម្មវិធីបណ្តុះបណ្តាលក្នុងឧស្សាហកម្ម ឬក្នុងគ្រឹះស្ថាន។

៥- ជំរុញឲ្យដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល ក្រុមហ៊ុនឯកជន និងសប្បុរសជន ពិនិត្យមើលលើលទ្ធភាពក្នុងការជួយផ្តល់អាហារូបករណ៍ដល់យុវជនក្រីក្រដែលចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

## ៤.៤- យុទ្ធសាស្ត្រទី៤: លើកកម្ពស់អភិបាលកិច្ចក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ

គោលបំណង គឺគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស ដើម្បីធានាថាការធ្វើអភិបាលកិច្ច ការគ្រប់គ្រង ការធ្វើផែនការសកម្មភាព ផែនការថវិកាកម្មវិធី ការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រ រួមទាំងការវាយតម្លៃ និងការរៀបចំរបាយការណ៍កាន់តែមានភាពប្រសើរឡើងជាបន្តបន្ទាប់។ លើសពីនេះ ប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ គឺជាប្រព័ន្ធដែលមានថាមវន្តនិងភាពបត់បែន ព្រមទាំងស្របតាមតម្រូវការរបស់និយោជក និងបច្ចេកវិទ្យាថ្មីៗ។ ការធ្វើអភិបាលកិច្ច ត្រូវធានាថាប្រព័ន្ធសមមូលនៃក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ត្រូវបានកែលម្អជាប្រចាំ និងដាក់ឲ្យដំណើរការ ដើម្បីគាំទ្រដល់ភាពជោគជ័យរបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ព្រមទាំងសិក្ខាកាម សិស្ស និស្សិត កម្លាំងពលកម្ម និងនិយោជក។

### ៤.៤.១- ពង្រឹងយន្តការក្របខណ្ឌគតិយុត្តសម្រាប់ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីភ្ជាប់ការបណ្តុះបណ្តាលជំនាញទៅនឹងតម្រូវការទីផ្សារការងារ

១- បន្តពង្រឹងតួនាទីលេខាធិការដ្ឋានរបស់គណៈកម្មាធិការជាតិបណ្តុះបណ្តាល ក្នុងការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

២- បន្តអនុវត្តគោលការណ៍វិមជ្ឈការក្នុងការគ្រប់គ្រងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីជំរុញបន្ថែមទៀតក្នុងការធ្វើសេចក្តីសម្រេច និងគណនេយ្យភាពសម្រាប់គ្រប់គ្រឹះស្ថាន។

៣- បន្តរៀបចំចងក្រងលិខិតបទដ្ឋានគតិយុត្តស្តីពីតួនាទីនិងភារកិច្ចរបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ស្របតាមបេសកកម្មនិងអាណត្តិរបស់ក្រសួងនិងអង្គភាព។

៤- ពង្រឹងសមត្ថភាពក្នុងការគ្រប់គ្រងគ្រឹះស្ថាន តាមរយៈប្រព័ន្ធកសាងសមត្ថភាពក្នុងភាពជាអ្នកដឹកនាំគ្រប់គ្រង និងគណនេយ្យភាព។

៥- ពង្រឹងសមត្ថភាពនិងគណនេយ្យភាពនៅតាមអង្គភាពនីមួយៗ ក្នុងការរៀបចំគោលនយោបាយ និងផែនការប្រតិបត្តិការប្រចាំឆ្នាំ ការធានាគុណភាព ព្រមទាំងការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ។

៦- រៀបចំគោលនយោបាយ បទបញ្ញត្តិ និងអភិបាលកិច្ច ព្រមទាំងពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រងនៅតាមអង្គភាពនីមួយៗ រួមទាំងគ្រឹះស្ថានឯកជន។

៧- ជំរុញគ្រប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ឲ្យបង្កើតក្រុមការងារទទួលបន្ទុកធ្វើទំនាក់ទំនងជាមួយសមាគមវិជ្ជាជីវៈ ស្ថាប័នផ្តល់សេវាកម្ម រោងចក្រ សហគ្រាស និងគ្រឹះស្ថាន ដើម្បីប្រមូលព័ត៌មានអំពីតម្រូវការជំនាញរបស់និយោជក និងជួយរកការងារឲ្យសិក្ខាកាម សិស្ស និស្សិតដែលបានបញ្ចប់ការសិក្សាដោយជោគជ័យ។

៨- លើកកម្ពស់គុណភាពគ្រប់គ្រងគ្រឹះស្ថាន តាមរយៈការប្រកួតប្រជែង និងរៀបចំឲ្យមានចំណាត់ថ្នាក់ក្នុងចំណោមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

៩- បន្តលើកទឹកចិត្តឲ្យមានកិច្ចសហប្រតិបត្តិការ និងកម្មវិធីផ្លាស់ប្តូរទស្សនកិច្ចសិក្សារវាងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ជាមួយគ្រឹះស្ថានទាំងក្នុងនិងក្រៅប្រទេស។

១០- បន្តកែលម្អលិខិតបទដ្ឋានគតិយុត្តនិងគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងការចុះបញ្ជិកាគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ឯកជន សមាគម និងអង្គការមិនមែនរដ្ឋាភិបាលឱ្យកាន់តែមានប្រសិទ្ធភាពនិងសុពលភាព។

១១- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃទៅលើភាពឆ្លើយតបនៃប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

១២- រៀបចំគោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្សដោយយកចិត្តទុកដាក់លើសមភាពយេនឌ័រ ដើម្បីទាក់ទាញគ្រូដែលមានសមត្ថភាពនិងរៀបចំកញ្ចប់ផលប្រយោជន៍(មិនមែនត្រឹមតែប្រាក់ឈ្នួលតែប៉ុណ្ណោះទេ) និងលក្ខខណ្ឌការងារល្អប្រសើរផងដែរ។

### ៤.៤.២- រៀបចំយន្តការផ្តល់មូលនិធិផ្អែកលើលទ្ធផលការងារ សម្រាប់ប្រតិបត្តិការរបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ

១- សិក្សាស្រាវជ្រាវអំពីប្រសិទ្ធភាពនៃយន្តការផ្តល់មូលនិធិសម្រាប់ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដោយផ្អែកលើលទ្ធផលការងាររបស់ស្ថាប័ននិងអង្គភាព។

២- សិក្សាស្រាវជ្រាវអំពីជម្រើសគំរូមួយចំនួនសម្រាប់គ្រូបច្ចេកទេសដែលឆ្លុះបញ្ចាំងពីតម្រូវការបទពិសោធក្នុងវិស័យឧស្សាហកម្មដែលជាធាតុចូលសំខាន់សម្រាប់ការបង្រៀនប្រកបដោយប្រសិទ្ធភាព។

៣- បន្តផ្តល់គោលការណ៍អនុញ្ញាតឲ្យគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈសាធារណៈអាចរកប្រាក់ចំណូល តាមមធ្យោបាយផ្សេងៗសមស្រប ដើម្បីធានាបាននូវនិរន្តរភាពរបស់គ្រឹះស្ថាន។

៤- ផ្តល់មូលនិធិឲ្យបានគ្រប់គ្រាន់សម្រាប់ការអភិវឌ្ឍគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

៥- រៀបចំការគ្រប់គ្រងហិរញ្ញវត្ថុរបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈសាធារណៈឲ្យមានតម្លាភាព តាមរយៈការកំណត់ឲ្យមានសន្ទស្សន៍បែងចែកប្រាក់ចំណូលដែលបានមកពីប្រភពផ្សេងៗឲ្យបានច្បាស់លាស់ និងបែងចែកខ្ទង់ចំណាយ ដូចជាការសាងសង់ ការថែទាំអគារ សម្ភារៈបរិក្ខារ និងការលើកទឹកចិត្តផ្សេងៗសម្រាប់មន្ត្រីរាជការ រួមមានបុគ្គលិក សាស្ត្រាចារ្យ និងថ្នាក់ដឹកនាំ។

៤.៤.៣- បន្តកែលម្អប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងប្រព័ន្ធព័ត៌មានទីផ្សារការងារ ព្រមទាំងពង្រឹងការវិភាគ ព្យាករណ៍ទីផ្សារការងារ និងការស្ទង់មតិលើតម្រូវការជំនាញ

១- អភិវឌ្ឍនិងថែទាំនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីប្រមូលព័ត៌មានពាក់ព័ន្ធនឹងការអភិវឌ្ឍជំនាញនិងប្រព័ន្ធព័ត៌មានទីផ្សារការងារ តាមរយៈកិច្ចសហការជាមួយភាគីពាក់ព័ន្ធ។

២- បន្តសិក្សាស្រាវជ្រាវនិងអភិវឌ្ឍប្រព័ន្ធព័ត៌មានទីផ្សារការងារ ព្រមទាំងប្រើប្រាស់លទ្ធផលនិងទិន្នន័យសម្រាប់រៀបចំផែនការបណ្តុះបណ្តាលឲ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ។

៣- ធ្វើការជាមួយក្រុមប្រឹក្សាជំនាញតាមវិស័យ ប្រមូលមតិត្រឡប់ (feedback) របស់និយោជកលើការបំពេញការងាររបស់កម្លាំងពលកម្មនិងប្រើប្រាស់ព័ត៌មានទាំងនោះជាធាតុចូលសម្រាប់កែលម្អចំណុចខ្វះខាតលើកម្មវិធីបណ្តុះបណ្តាលជំនាញ។

៤- សិក្សាអំពីតម្រូវការបណ្តុះបណ្តាលជំនាញនិងធ្វើបញ្ជីឈ្មោះមុខរបរ ដាក់លេខកូដសម្គាល់ ដើម្បីជាមូលដ្ឋានសម្រាប់ផ្តល់ការបណ្តុះបណ្តាលដែលស្របតាមតម្រូវការឧស្សាហកម្ម និយោជក និងសហគមន៍។

៥- ប្រមូល វិភាគ និងរៀបចំរបាយការណ៍ស្តីពីព័ត៌មានរបស់និយោជកនិងតម្រូវការកម្លាំងពលកម្មក្នុងពេលអនាគតតាមប្រភេទនៃមុខរបរ ជំនាញ និងវិស័យទាំងក្នុង និងក្រៅប្រទេស។

## ៥- ផែនការសកម្មភាព

ដើម្បីសម្រេចយុទ្ធសាស្ត្រខាងលើ ត្រូវយកចិត្តទុកដាក់លើសកម្មភាពមួយចំនួនដូចខាងក្រោមនេះ៖

### ៥.១- ការបង្កើតយន្តការ

ដើម្បីសម្រេចបាននូវសកម្មភាពអាទិភាពខាងលើ គណៈកម្មាធិការជាតិបណ្តុះបណ្តាលតាមរយៈក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈជាលេខាធិការដ្ឋាន ត្រូវរៀបចំនិងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន អង្គការពាក់ព័ន្ធនឹងសហការគ្នាយ៉ាងជិតស្និទ្ធ ក្នុងការបង្កើតឲ្យមានយន្តការសម្របសម្រួលផ្ទៃក្នុងមួយ ក្នុងគោលបំណងកែសម្រួល និងឆ្លើយតបភ្លាមៗ ឬត្រៀមធ្វើជាធាតុចូលក្នុងផែនការយុទ្ធសាស្ត្រ នាពេលខាងមុខ។

៥.២- ការបង្កើតក្របខណ្ឌគតិយុត្ត

គណៈកម្មាធិការជាតិបណ្តុះបណ្តាលតាមរយៈក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាលេខាធិការដ្ឋាន ត្រូវបន្តជំរុញការរៀបចំបទដ្ឋានគតិយុត្តផ្សេងៗបន្ថែមទៀត ក្នុងការអភិវឌ្ឍវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ រួមមាន៖

- ច្បាប់ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ
- គោលនយោបាយស្តីពីប្រព័ន្ធឥណទានសម្រាប់ការសិក្សាវិជ្ជាជីវៈ
- គោលនយោបាយស្តីពីការបង្កើតមូលនិធិអភិវឌ្ឍជំនាញ
- គោលនយោបាយស្តីពីការគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ ឯកជន អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិដែលទទួលបន្ទុកការងារអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ល។

៥.៣- ការគាំទ្រហិរញ្ញវត្ថុ

ដើម្បីអនុវត្តសកម្មភាពគាំទ្រ គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈឆ្នាំ ២០១៧-២០២៥ គណៈកម្មាធិការជាតិបណ្តុះបណ្តាលនិងក្រសួងស្ថាប័នពាក់ព័ន្ធ អាចប្រើប្រាស់ថវិការដ្ឋក្នុងក្របខណ្ឌនៃថវិកាប្រចាំឆ្នាំ ឬមូលនិធិដែលទទួលបានពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការជាមួយដៃគូជាតិ អន្តរជាតិ និងពីប្រភពផ្សេងៗទៀត។

៥.៤- ការបណ្តុះបណ្តាលធនធានមនុស្ស

ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ត្រូវយកចិត្តទុកដាក់បណ្តុះបណ្តាលបង្កើនសមត្ថភាពមន្រ្តីតាមក្រសួង ស្ថាប័នពាក់ព័ន្ធលើជំនាញផ្សេងៗ ដោយត្រូវរៀបចំក្នុងការជំរុញរៀបចំផែនការសកម្មភាព និងអនុវត្តគោលនយោបាយជាតិនេះឲ្យកាន់តែមានប្រសិទ្ធភាព។

៥.៥- ដំណើរការអនុវត្តគម្រោង

ផែនការសកម្មភាពត្រូវបានរៀបចំប្រចាំឆ្នាំនិងប្រាំឆ្នាំម្តង តាមការប្រជុំពិគ្រោះយោបល់ជាមួយនឹងដៃគូពាក់ព័ន្ធ ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយជាតិនេះ។ ផែនការត្រូវបង្ហាញពីចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ក្នុងការជំរុញការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ នឹងត្រូវឆ្លើយតបទៅនឹងផែនការយុទ្ធសាស្រ្តអភិវឌ្ឍជាតិ និងឯកសារគតិយុត្តនានារបស់រាជរដ្ឋាភិបាល ហើយផែនការនេះក៏ត្រូវអនុវត្តនៅក្នុងក្របខណ្ឌកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល។

## ៦- ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ

ដើម្បីធានាវឌ្ឍនភាព ប្រសិទ្ធភាព និងប្រសិទ្ធផលក្នុងការតាមដាននិងការអនុវត្តគោលនយោបាយជាតិនេះ រាជរដ្ឋាភិបាល ប្រគល់ភារកិច្ចដល់គណៈកម្មាធិការជាតិបណ្តុះបណ្តាល តាមរយៈក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈជាលេខាធិការដ្ឋានឲ្យរៀបចំនិងសម្របសម្រួលការអនុវត្តឲ្យមានប្រសិទ្ធភាពនូវប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ រួមមានការរៀបចំរបាយការណ៍ប្រចាំឆ្នាំ ស្តីពីការអនុវត្តនិងអនុលោមតាមគោលនយោបាយជាតិនេះ ដាក់ជូនទៅរាជរដ្ឋាភិបាល។ តាមរយៈនេះ គណៈកម្មាធិការជាតិបណ្តុះបណ្តាលធ្វើការកំណត់បញ្ហាប្រឈម ដោយផ្អែកលើគោលដៅនិងសូចនាករ ដើម្បីជាមូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេចលើវិធានការបន្ទាន់ចាំបាច់ សម្រាប់ធ្វើការដោះស្រាយបញ្ហាចំពោះមុខដែលកើតឡើង ក្នុងពេលអនុវត្តគោលនយោបាយនេះ។

វិធានការនីមួយៗត្រូវមានផែនការអនុវត្តដែលមានថិរវេលាជាក់លាក់។ លទ្ធផលនិងផលប៉ះពាល់ដែលកើតចេញពីការអនុវត្តផែនការនេះត្រូវមានលក្ខណៈអាចវាស់វែងបាន ហើយផែនការអនុវត្តនីមួយៗត្រូវភ្ជាប់មកជាមួយនូវការប៉ាន់ស្មានទំហំថវិកាដែលត្រូវការ។

## ៧- សេចក្តីសន្និដ្ឋាន

"គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ឆ្នាំ២០១៧-២០២៥" គឺជាផ្នែកមួយនៃផែនទីចង្អុលផ្លូវរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអភិវឌ្ឍវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ជាពិសេស ការអភិវឌ្ឍជំនាញតាមរយៈការផ្តល់នូវជំនាញ សមត្ថភាព និងចំណេះដឹងទាក់ទងនឹងការងារដល់ប្រជាជនកម្ពុជាគ្រប់រូបសម្រាប់ការងារពេញមួយជីវិតប្រកបដោយផលិតភាពខ្ពស់និងការប្រកួតប្រជែងទាំងក្នុងនិងក្រៅប្រទេស។

គោលនយោបាយនេះមានចក្ខុវិស័យទូលំទូលាយដោយផ្អែកលើគោលបំណងធំៗចំនួន៤គឺ **ទី១.** ពង្រឹងគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ **ទី២.** បង្កើនលទ្ធភាពទទួលបានការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ **ទី៣.** លើកទឹកចិត្តភាពជាដៃគូរវាងរដ្ឋ ឯកជន និង**ទី៤.** អភិបាលកិច្ចនៃប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។

ពេលវេលាអនុវត្តគោលនយោបាយជាតិនេះ មានភាពសមស្របទៅនឹងស្ថានភាពសេដ្ឋកិច្ចសង្គមនាពេលបច្ចុប្បន្នដែលជាប្រទេសមានចំណូលមធ្យមកម្រិតទាប ហើយកំពុងប្រែក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។ ការកំណត់គោលដៅជំនាញនៃកម្លាំងពលកម្មគឺជាការចាំបាច់បំផុត ដោយយកចិត្តទុកដាក់ ជាពិសេសទៅលើយុវជនដ៏ច្រើនលើសលុបដែលកំពុងសិក្សា ក៏ដូចជាសិស្សដែលបានបោះបង់ការសិក្សា ហើយមិនមានលទ្ធភាពបន្តការបណ្តុះបណ្តាលវិជ្ជាជីវៈផ្លូវការ ការងារទាំងនេះទាមទារឲ្យមានភាពជាដៃគូជាមួយវិស័យឧស្សាហកម្មក្នុងការបណ្តុះបណ្តាលផងដែរ។ ការទាក់ទាញវិនិយោគបរទេសផ្អែកលើកម្លាំងពលកម្មដែលមានជំនាញឲ្យទទួលបានប្រាក់ខែខ្ពស់ គឺជាបញ្ហាប្រឈមមួយដែលគោលនយោបាយនេះត្រូវរៀបចំក្របខណ្ឌមួយ ដើម្បីធ្វើការផ្លាស់ប្តូរដោយផ្តោតទៅលើភាពជាដៃគូគ្រប់កម្រិត ដោយរួបរួមគ្នាអភិវឌ្ឍសេដ្ឋកិច្ចសង្គមនាពេលអនាគត។

ផ្អែកលើគោលនយោបាយនេះ រាជរដ្ឋាភិបាលសង្ឃឹមថាស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ អង្គការ សហគមន៍ គ្រួសារ បុគ្គល និងគ្រឹះស្ថានសិក្សានឹងចូលរួមចំណែកអនុវត្តគោលនយោបាយស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈនេះឲ្យបានជោគជ័យ។

## ៨- សន្ទានុក្រម

| ល.រ. | វាក្យសព្ទ | ភាសាអង់គ្លេស | សេចក្តីពន្យល់ |
|---|---|---|---|
| ១ | ការចុះបញ្ជី | Registration | សំដៅដល់ដំណើរការនៃការផ្តល់ឲ្យគ្រឹះស្ថាននូវឱកាសដើម្បីបង្កើនទំនាក់ទំនង ដែលមានការទទួលស្គាល់ជាផ្លូវការនិងជាសាធារណៈជាមួយស្ថាប័ន ជាតិពាក់ព័ន្ធ(អាជ្ញាធរមានសមត្ថកិច្ច)។ |
| ២ | ការធានាគុណភាព | Quality Assurance | សំដៅដល់ពាក្យទូទៅសម្រាប់គ្រប់សកម្មភាពដែលធានាថាសេវានៃការអប់រំនិងការបណ្តុះបណ្តាលរបស់គ្រឹះស្ថានឬអង្គភាពត្រូវបានផ្តល់ប្រកបដោយប្រសិទ្ធភាពជាប់ជានិច្ច ទៅតាមតម្រូវការស្តង់ដានិងស្របតាមគោលដៅនិងគោលបំណងដែលបានផ្សព្វផ្សាយ។ |
| ៣ | ការបណ្តុះបណ្តាលក្នុងឧស្សាហកម្ម | In-industry Training | សំដៅដល់ការបណ្តុះបណ្តាលដែលធ្វើឡើងនៅក្នុងក្រុមហ៊ុនឬឧស្សាហកម្ម។ |
| ៤ | ការទទួលស្គាល់គុណភាពអប់រំ | Accreditation | សំដៅដល់ដំណើរការតាមរយៈសមាគមឬអង្គភាពទទួលខុសត្រូវស្របច្បាប់ ដើម្បីផ្តល់ការទទួលស្គាល់ជាសាធារណៈទៅលើសាលា វិទ្យាស្ថាន មហាវិទ្យាល័យ សាកលវិទ្យាល័យ ឬកម្មវិធីអប់រំដែលបំពេញបាននូវស្តង់ដាអប់រំអប្បបរមា។ តាមនិយមន័យរបស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជាគឺជាការអនុម័តជាផ្លូវការរបស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា តាមនីតិវិធីដែលបានកំណត់ដោយប្រកាសថា គ្រឹះស្ថានឧត្តមសិក្សាបានបំពេញសមស្របតាមលក្ខខណ្ឌ ឬលក្ខណវិនិច្ឆ័យ ឬស្តង់ដាគុណភាពអប្បបរមារបស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា និងទទួលបានសិទ្ធិចេញវិញ្ញាបនបត្រ ឬសញ្ញាបត្រគ្រប់កម្រិតក្នុងរយៈពេលមួយកំណត់។ |
| ៥ | ការទទួលស្គាល់ការសិក្សាដែលមានពីមុន | Recognition of Prior learning ( RPL ) | សំដៅដល់ការទទួលស្គាល់និងផ្តល់សុពលភាពសម្រាប់គោលបំណងនៃការធ្វើវិញ្ញាបនកម្ម (ការបញ្ជាក់) ដែលបានពីក្រៅប្រព័ន្ធអប់រំ និងបណ្តុះបណ្តាលផ្លូវការ។ |
| ៦ | ការទទួលស្គាល់សមត្ថភាពបច្ចុប្បន្ន | Recognition of Current Competencies( RCC ) | សំដៅដល់ដំណើរការទទួលបានក្រេឌីតសម្រាប់សមត្ថភាពដែលអ្នកសិក្សានិងអ្នកធ្វើការមានរួចហើយ។ ភស្តុតាងដែលបេក្ខជនផ្តល់ទៅអ្នកវាយតម្លៃសមត្ថភាព ត្រូវបានវាយតម្លៃធៀបនិងគុណវឌ្ឍិនិងស្តង់ដាសមត្ថភាព ដើម្បីកំណត់ថាតើបេក្ខជនមានសមត្ថភាព ស្របតាមគុណវឌ្ឍិឬស្តង់ដាសមត្ថភាពកម្រិតណាមួយ។ |
| ៧ | ការវាយតម្លៃ | Assessment | សំដៅដល់ដំណើរការនៃការប្រមូលភស្តុតាងដើម្បីបញ្ជាក់ថាតើអ្នកសិក្សាទទួលបានជំនាញស្របតាមស្តង់ដាដែរឬទេ។ ការវាយតម្លៃក៏ត្រូវបានប្រើជាផ្នែកមួយនៃដំណើរការសិក្សាដើម្បីជួយដល់អ្នកសិក្សាក្នុងការធ្វើឲ្យមានការរីកចម្រើន(វឌ្ឍនភាពផ្នែកចំណេះដឹង ជំនាញ និងសមត្ថភាព)។ តាមនិយមន័យរបស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ការវាយតម្លៃ គឺជាយន្តការមួយនៃដំណើរការទទួលស្គាល់ គុណភាពអប់រំ ដែលត្រូវធ្វើការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សាដោយក្រុមមន្ត្រី វាយតម្លៃផ្អែកលើនីតិវិធី សេចក្តីណែនាំ លក្ខខណ្ឌ ឬលក្ខណវិនិច្ឆ័យ ឬស្តង់ដាគុណភាពអប្បរមារបស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា និងរបាយការណ៍ស្វ័យវាយតម្លៃរបស់គ្រឹះស្ថានដែលបានផ្ញើជូនទៅគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ដើម្បីផ្តល់ការទទួលស្គាល់ |

| | | | |
|---|---|---|---|
| | | | គុណភាពអប់រំ និងធ្វើឲ្យប្រសើរឡើងនូវគុណភាពអប់រំឧត្តមសិក្សា។ |
| ៨ | ការវាយតម្លៃផ្អែកលើសមត្ថភាព | Competency Based Assessment | សំដៅដល់ដំណើរការនៃការប្រមូលភស្តុតាង ដើម្បីបញ្ជាក់ថាតើអ្នកសិក្សាបានសម្រេចតាមស្តង់ដារដែលតម្រូវឬទេ។ ការវាយតម្លៃក៏ត្រូវបានប្រើជាផ្នែកនៃដំណើរការសិក្សា ដើម្បីជួយដល់អ្នកសិក្សាក្នុងការធ្វើឲ្យមានការរីកចម្រើន(វឌ្ឍនកម្មផ្នែកចំណេះដឹង ជំនាញ និងសមត្ថភាព)។ |
| ៩ | កម្មវិធីបណ្តុះបណ្តាលជំនាញ | Skills Training Program | សំដៅដល់កម្មវិធីបណ្តុះបណ្តាលផ្អែកលើមុខរបរ នៅពេលបានបញ្ចប់ពេញលេញនិងវាយតម្លៃរួច បានជាក្រេឌីត ឈានឆ្ពោះទៅដល់ការទទួលបានគុណវុឌ្ឍិពេញលេញឬផ្នែកនៃគុណវុឌ្ឍិ ស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា។ |
| ១០ | កម្មវិធីសិក្សា | Curriculum | សំដៅដល់សំណុំនៃការងារទៅតាមពេលនៃការអភិវឌ្ឍកម្មវិធីសិក្សា រួមមានការកំណត់គោលដៅ ខ្លឹមសារ វិធីសាស្ត្រ(រួមទាំងការវាយតម្លៃ) និងសម្ភារៈនៃការបណ្តុះបណ្តាល។ តាមនិយមន័យរបស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា កម្មវិធីសិក្សាសំដៅដល់សំណុំមុខវិជ្ជា ដែលត្រូវបានរៀបចំឲ្យអ្នកសិក្សាទទួលបាននូវចំណេះដឹង ចំណេះធ្វើ សីលធម៌ និងសមត្ថភាពបន្តការសិក្សាពេញមួយជីវិត។ |
| ១១ | កម្មវិធីស្ពានចម្លងបន្តជំនាញ | Skill Bridging Program | សំដៅដល់កម្មវិធីបណ្តុះបណ្តាលដើម្បីបំពេញចំណេះដឹងដល់យុវជននិងយុវនារីដែលពុំមានឱកាសសិក្សានៅថ្នាក់ទី៧ ថ្នាក់ទី៨ និងថ្នាក់ទី៩ នៃសាលាចំណេះទូទៅ ដើម្បីឲ្យពួកគេអាចបន្តការសិក្សាក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ |
| ១២ | ក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា | Cambodian Qualifications Framework(CQF) | សំដៅដល់លិខិតូបករណ៍ថ្នាក់ជាតិសម្រាប់ធ្វើការអភិវឌ្ឍនិងធ្វើចំណាត់ថ្នាក់នៃគុណវុឌ្ឍិស្របតាមលក្ខណវិនិច្ឆ័យនៃកម្រិតសិក្សាដែលបានសម្រេច ហើយក៏ជាគោលនយោបាយ និងយុទ្ធសាស្ត្រមួយក្នុងការធានាបាននូវគុណភាពអប់រំនិងបណ្តុះបណ្តាល ដែលធ្វើឲ្យលទ្ធផលសិក្សាមានលក្ខណៈស្តង់ដាច្បាស់លាស់ ព្រមទាំងមានការទទួលស្គាល់យ៉ាងទូលំទូលាយនៅក្នុងសហគមន៍ជាតិនិងអន្តរជាតិ។ |
| ១៣ | ក្រុមប្រឹក្សាជំនាញតាមវិស័យ | Sector Skills Councils | សំដៅដល់តំណាងអាជីវកម្មជាន់ខ្ពស់ពីវិស័យសេដ្ឋកិច្ចជាក់លាក់ណាមួយ(ដូចជាទេសចរណ៍ សំណង់) ដែលត្រូវបានចាត់តាំងដោយក្រសួងទទួលបន្ទុកសម្រាប់វិស័យនោះ។ ក្រុមប្រឹក្សាជំនាញតាមវិស័យទទួលបន្ទុកចូលរួមក្នុងការអនុម័តលើស្តង់ដាជំនាញសម្រាប់ការងារនីមួយៗក្នុងវិស័យ និងផ្តល់អានុសាសន៍ក្នុងការដាក់បញ្ចូលស្តង់ដាទាំងនោះទៅក្នុងក្របខណ្ឌគុណវុឌ្ឍិជាតិ។ ក្រុមប្រឹក្សាជំនាញតាមវិស័យអាចមានតួនាទីផ្សេងទៀតយោងទៅតាមការចាត់តាំងពីគណកម្មាធិការជាតិបណ្តុះបណ្តាល។ |
| ១៤ | គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ | Technical Vocational Education and Training Institutions | សំដៅលើវិទ្យាស្ថាន មជ្ឈមណ្ឌល សាលាមធ្យមសិក្សាបច្ចេកទេសទាំងឡាយណាដែលផ្តល់វគ្គសិក្សាពាក់ព័ន្ធនឹងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ |
| ១៥ | ជំនាញ | Skills | សំដៅដល់សមត្ថភាពប្រើប្រាស់ចំណេះដឹងដើម្បីបំពេញការងារនិងដោះស្រាយបញ្ហា។ ជំនាញត្រូវបានពិពណ៌នាជាចំណេះដឹង វិភាគ(ការប្រើគំនិតប្រកបដោយភាពត្រឹមត្រូវ អព្ភន្តរញាណ និងការច្នៃប្រឌិត) និងការអនុវត្ត(ទាក់ទងនឹងទេពកោសល្យហត្ថកម្ម |

| | | | |
|---|---|---|---|
| | | | ជំនាញប្រើដោយដៃ និងការប្រើវិធីសាស្រ្ត សម្ភារៈ ឧបករណ៍ និងគ្រឿងប្រដាប់ផ្សេងៗ)។ |
| ១៦ | ជំនាញទន់ | Soft Skills | សំដៅដល់ជំនាញមិនមែនបច្ចេកទេសដែលបុគ្គលម្នាក់ៗត្រូវការចាំបាច់ ដើម្បីប្រតិបត្តិការងារឲ្យត្រូវតាមតម្រូវការក្នុងកន្លែងការងារនិងសង្គម ដែលជំនាញទាំងនេះអាចផ្ទេរនិងយកទៅអនុវត្តនៅគ្រប់ការងារនិងឧស្សាហកម្មទៅតាមកម្រិតដែលគេបានកំណត់។ |
| ១៧ | ជំនាញបៃតង | Green skills | សំដៅដល់ជំនាញបច្ចេកទេស ចំណេះដឹង គុណតម្លៃ និងឥរិយាបថដែលកម្លាំងពលកម្មត្រូវការ ដើម្បីគាំទ្រ និងអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងបរិស្ថានឲ្យទទួលបានលទ្ធផលប្រកបដោយនិរន្តរភាព ដែលជាទូទៅត្រូវបានទទួលស្គាល់ថាជាជំនាញសម្រាប់និរន្តរភាពឬជំនាញបៃតង។ |
| ១៨ | ផលិតភាព | Productivity | សំដៅដល់លទ្ធភាពក្នុងការផលិត។ |
| ១៩ | ផលិតភាពការងារ | Labor Productivity | សំដៅដល់ទិន្នផលការងារដែលកម្លាំងពលកម្មម្នាក់សម្រេចបានក្នុងបរិវេលាកំណត់មួយ (ឧទាហរណ៍ ក្នុងមួយម៉ោង)។ |
| ២០ | មជ្ឈមណ្ឌលវាយតម្លៃជំនាញថ្នាក់ជាតិ | National Skills Assessment Centers | សំដៅដល់មជ្ឈមណ្ឌលដែលទទួលបានការទទួលស្គាល់គុណភាពពីអាជ្ញាធរមានសមត្ថកិច្ច ដើម្បីផ្តល់សេវាវាយតម្លៃជំនាញផ្អែកលើសមត្ថភាព រួមទាំងការទទួលស្គាល់ការសិក្សាដែលមានពីមុន និងការទទួលស្គាល់សមត្ថភាពបច្ចុប្បន្ន។ |
| ២១ | សមត្ថភាព | Competence | សំដៅដល់លទ្ធភាពក្នុងការអនុវត្តនូវចំណេះដឹង និងជំនាញដែលមាន។ សមត្ថភាពរួមមាន៖<br>- សមត្ថភាពយល់ដឹងក្នុងការគិតពាក់ព័ន្ធនឹងការប្រើទ្រឹស្តីនិងទស្សនៈ ព្រមទាំងចំណេះដឹងគិតគូរទទួលបានតាមរយៈបទពិសោធ<br>- សមត្ថភាពក្នុងការបំពេញមុខងារ(ជំនាញ ការដឹងពីរបៀបធ្វើ) គឺជាលទ្ធភាពសម្រេចបាននូវការងារដែលបានប្រគល់ឲ្យ<br>- សមត្ថភាពផ្ទាល់ខ្លួន សំដៅដល់លទ្ធភាពអាចធ្វើបានដោយខ្លួនឯង នៅក្នុងស្ថានភាពការងារជាក់លាក់ណាមួយ និង<br>- សមត្ថភាពក្រមសីលធម៌ សំដៅដល់គុណតម្លៃផ្ទាល់ខ្លួន និងគុណតម្លៃខាងវិជ្ជាជីវៈ។ |
| ២២ | ស្តង់ដាសមត្ថភាព | Competency Standard | សំដៅដល់សេចក្តីបញ្ជាក់ដែលបានបង្កើតនិងអនុម័តជាផ្លូវការដោយអង្គភាពនិងស្ថាប័នមានសមត្ថកិច្ច ដែលកំណត់វិធានដែលត្រូវអនុវត្តតាមបរិបទដែលបានផ្តល់ជូន ឬលទ្ធផលដែលត្រូវសម្រេចបាន។ ស្តង់ដាសមត្ថភាពសំដៅចំពោះចំណេះដឹង ជំនាញ និងសមត្ថភាពដែលមានទំនាក់ទំនងនឹងការអនុវត្តមុខរបរ។ |
| ២៣ | សួនបច្ចេកទេសនិងវិជ្ជាជីវៈ | Technical and Vocational Park | សំដៅដល់បណ្តុំឬចង្កោមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដែលធ្វើការចែករំលែក និងប្រើប្រាស់នូវធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងធនធានរូបវន្តក្នុងចំណោមគ្រឹះស្ថាន ដើម្បីអាចឲ្យសិស្សប្រើប្រាស់ក្នុងការអនុវត្តនូវជំនាញរបស់ពួកគេ។ លើសពីនេះ សួនបច្ចេកទេសនិងវិជ្ជាជីវៈក៏ប្រើប្រាស់ជាវេទិកាមួយសម្រាប់៖<br>- ពង្រឹងគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ តាមរយៈការប្រកួតប្រជែងក្នុងការស្វែងរកសិស្ស និស្សិត ឬបុគ្គលដែលឆ្នើម ព្រមទាំងការតាំងបង្ហាញនូវសមិទ្ធផល ក៏ដូចជារបកគំហើញបច្ចេកវិទ្យាថ្មីៗរបស់ពួកគេ ដើម្បីទាក់ទាញការចូលរួម និងវិនិយោគពីវិស័យឯកជន។<br>- ផ្តល់នូវដំណោះស្រាយបញ្ហាដែលជាកង្វល់របស់ឧស្សាហកម្ម ក៏ដូចជាវិស័យឯកជនផងដែរ តាមរយៈការបណ្តុះបណ្តាលធនធាន |

| | | | |
|---|---|---|---|
| | | | មនុស្សទៅតាមតម្រូវការទីផ្សារការងារជាក់ស្តែង ព្រមទាំងការផ្តល់សេវាថែទាំនិងជួសជុលក្នុងខ្សែចង្វាក់ផលិតកម្មនិងគ្រឿងម៉ាស៊ីន។ |
| ២៤ | ការបណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់ | Voucher Skills Traning Program | សំដៅដល់កម្មវិធីបណ្តុះបណ្តាលមួយដែលផ្តល់អនុភាពទៅក្រុមគោលដៅ(រួមមាន យុវជនបោះបង់ការសិក្សា គ្រួសារដែលមានស្ត្រីជាមេគ្រួសារជនពិការ អ្នកដែលគ្មានការងារធ្វើ ជនក្រីក្រ ជនជាតិភាគតិច) និងឆ្លើយតបតាមតម្រូវការរបស់សហគមន៍។ ការបណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់មានចំនួន៣ប្រភេទគឺ១- ការបណ្តុះបណ្តាលនៅតាមសហគមន៍ ២- ការបណ្តុះបណ្តាលនៅតាមសហគ្រាស និង៣- ការបណ្តុះបណ្តាលនៅតាមមជ្ឈមណ្ឌល។ |

# ឧបសម្ព័ន្ធ តារាងវិធានការគោលនយោបាយ

| គោលបំណងនិងគោលដៅ | យុទ្ធសាស្ត្រ | រយៈពេល/ឆ្នាំ | ស្ថាប័ននាំមុខ/ទទួលខុសត្រូវអនុវត្ត |
| --- | --- | --- | --- |
| គោលបំណង៣.១.១ ពង្រឹងគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ឲ្យស្របតាមតម្រូវការទីផ្សារការងារក្នុងនិងក្រៅប្រទេស | | | |
| គោលដៅ ៣.២.១.១ បន្តរៀបចំនិងអនុវត្តប្រព័ន្ធធានាគុណភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ផ្អែកលើក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា។ | ១- រៀបចំលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីគាំទ្រក្នុងការត្រួតពិនិត្យ តាមដាន និងវាយតម្លៃសម្រាប់ការអនុវត្តក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ស្របតាមការអភិវឌ្ឍវិស័យឧស្សាហកម្ម។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងទេសចរណ៍<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ២- ធ្វើការសម្របសម្រួលឲ្យមានការទទួលស្គាល់អំពីកម្រិតគុណវុឌ្ឍិរវាងក្របខណ្ឌជាតិកម្ពុជា ជាមួយនឹងក្របខណ្ឌគុណវុឌ្ឍិយោងអាស៊ាន ក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៣- ពង្រឹងការអនុវត្តធានាគុណភាព ត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដោយប្រើប្រាស់លក្ខណវិនិច្ឆ័យដែលបានកំណត់ស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ដើម្បីជំរុញការប្រកួតប្រជែងគុណភាពនិងសេវា។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៤- អភិវឌ្ឍនិងអនុវត្តផែនការសកម្មភាព គោលការណ៍ណែនាំនិងនីតិវិធីនៃលក្ខណវិនិច្ឆ័យសម្រាប់ទទួលស្គាល់វគ្គ កម្មវិធីបណ្តុះបណ្តាល និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៥- អភិវឌ្ឍនិងអនុវត្តការវាយតម្លៃផ្អែកលើសមត្ថភាពឬលទ្ធផលសិក្សា ការធ្វើតេស្តសមត្ថភាព ការទទួលស្គាល់ ការសិក្សាពីមុន និងការទទួលស្គាល់សមត្ថភាពនាពេលបច្ចុប្បន្ន ព្រមទាំងការផ្តល់លិខិតបញ្ជាក់ វិញ្ញាបនបត្រ សញ្ញាបត្រ និងអាជ្ញាបណ្ណ។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៦- រៀបចំបទដ្ឋានគតិយុត្តស្តីពីការផ្តល់វិញ្ញាបនបត្រដែលចេញពីនីតិវិធីក្នុងការទទួលស្គាល់សមត្ថភាព ស្របតាមកម្រិតនៃក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |

| | | | |
|---|---|---|---|
| | ៧- បង្កើតមជ្ឈមណ្ឌលថ្នាក់ជាតិសម្រាប់ធ្វើតេស្តជំនាញបញ្ជាក់សមត្ថភាព ដើម្បីគាំទ្រដល់មុខរបរនិងជំនាញអាទិភាព។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៨- រៀបចំក្របខណ្ឌនិងស្តង់ដាសម្រាប់ការអប់រំចំណេះទូទៅ និងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីផ្តល់ភាពងាយស្រួលក្នុងការផ្ទេរពីគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈទៅគ្រឹះស្ថានឧត្តមសិក្សា។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៩- កំណត់យកអង្គភាពក្នុងក្រសួងឬគ្រឹះស្ថានផ្តល់ការបណ្តុះបណ្តាល ដើម្បីធ្វើជាអង្គភាពបង្គោលក្នុងការសម្របសម្រួលអនុវត្ត និងថែរក្សានូវប្រព័ន្ធធានាគុណភាពសម្រាប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ទាំងស្ថាប័នសាធារណៈ ឯកជន និងអង្គការមិនមែនរដ្ឋាភិបាល។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ១០- បណ្តុះបណ្តាលដល់មន្ត្រី បុគ្គលិករបស់គ្រឹះស្ថានសិក្សាអំពីនីតិវិធីស្វ័យវាយតម្លៃនិងតម្រូវការនានា ដើម្បីទទួលបានការទទួលស្គាល់គុណភាពអប់រំ បណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ១១- រៀបចំវាយតម្លៃគុណភាពជំនាញ តាមរយៈការប្រើប្រាស់កម្រងសំណួរលើបណ្តាញអ៊ីនធឺណែតដល់ភាគីពាក់ព័ន្ធ រួមទាំងសិស្សដែលបានបញ្ចប់ការសិក្សាឲ្យបានទៀងទាត់។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| គោលដៅ៣.២.១.២ ពង្រឹងគុណភាពនិងគរុកោសល្យរបស់គ្រូបណ្តុះបណ្តាល ហេដ្ឋារចនាសម្ព័ន្ធ រួមទាំងធនធានមូលដ្ឋានសម្រាប់រៀន និងបង្រៀន ឲ្យឆ្លើយតបតាមការអភិវឌ្ឍបច្ចេកវិទ្យាថ្មីនិងតម្រូវការរបស់ទីផ្សារការងារ។ | ១- រៀបចំចងក្រងលិខិតបទដ្ឋានគតិយុត្តដែលតម្រូវឲ្យគ្រូបច្ចេកទេសឆ្លងកាត់វគ្គបណ្តុះបណ្តាលស្តីពីគរុកោសល្យ ព្រមទាំងបង្កើនជំនាញឧស្សាហកម្មជាប្រចាំ។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងទេសចរណ៍<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ២- លើកកម្ពស់សមត្ថភាពនិងគុណវុឌ្ឍិគ្រូបច្ចេកទេស ជាពិសេស ស្ត្រីលើជំនាញនិងគរុកោសល្យ ដើម្បីទទួលបាននូវបទពិសោធថ្មីៗពីផ្នែកឧស្សាហកម្មទាំងក្នុងនិងក្រៅប្រទេស។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងទេសចរណ៍<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៣- បណ្តុះបណ្តាលគ្រូបច្ចេកទេសអំពីស្តង់ដាសមត្ថភាព ការវាយតម្លៃផ្អែកលើសមត្ថភាព ការរៀបចំឯកសារ កញ្ចប់សិក្សា និងសម្ភារៈវាយតម្លៃដែលជាតម្រូវការរបស់ស្ថាប័នទទួលបន្ទុក។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងទេសចរណ៍<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៤- រៀបចំផែនការបង្កើនសមត្ថភាពវិជ្ជាជីវៈប្រចាំឆ្នាំតាមកម្រិតសម្រាប់គ្រូបច្ចេកទេស នៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាល | ២០១៧ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |

| | | | |
|---|---|---|---|
| | បច្ចេកទេសនិងវិជ្ជាជីវៈ។ | ទៅ ២០២៥ | - ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៥- កែលម្អហេដ្ឋារចនាសម្ព័ន្ធនិងធនធានមូលដ្ឋាន រួមមានសម្ភារៈឧបទេស រោងជាង ឯកសារ បណ្ណាល័យដោយមានភ្ជាប់សេវាអ៊ីនធឺណែតនៅតាមគ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ឲ្យបានគ្រប់គ្រាន់ដោយផ្អែកលើត្រូវការបណ្ដុះបណ្ដាល និងការរីកចម្រើនរបស់ឧស្សាហកម្ម។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៦- ពិនិត្យលទ្ធផលប្រើប្រាស់ធនធានដែលអាចប្រើប្រាស់រួមគ្នាបាន ក្នុងចំណោមគ្រឹះស្ថានអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីធ្វើឲ្យសិស្សទទួលបានការអប់រំមូលដ្ឋាន និងជំនាញបញ្ចូលគ្នាដែលជាផ្នែកមួយនៃកម្មវិធីសិក្សា។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៧- ពង្រឹងគុណភាពគ្រឹះស្ថានបណ្ដុះបណ្ដាលគរុនិស្សិតដោយផ្សារភ្ជាប់ទ្រឹស្ដីទៅនឹងឱកាសធ្វើកម្មសិក្សានៅក្នុងឧស្សាហកម្ម។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៨- លើកកម្ពស់សមភាពយេនឌ័រ តាមរយៈការជំរុញលើកទឹកចិត្តស្ត្រីឲ្យធ្វើជាគ្រូ និងអ្នកគ្រប់គ្រងនៅក្នុងគ្រឹះស្ថាន អប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ ទៅតាមចំនួនកំណត់អតិបរមា។ | ២០១៧ ទៅមធ្យម | - ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៩- កំណត់នូវវិធានការលើកទឹកចិត្តគ្រូដែលត្រូវបំពេញការងារតាមខេត្តឲ្យបំពេញតួនាទីទៅតាមការចាត់តាំង ប្រកបដោយប្រសិទ្ធភាព។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ១០- រៀបចំវិធានការទាក់ទាញអ្នកវិទ្យាសាស្ត្រ អ្នកបច្ចេកទេសឆ្នើមៗនិងសិស្សពូកែៗឲ្យងាកមករៀន ឬបម្រើការងារក្នុងវិស័យអប់រំបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ។ | ២០១៧ ទៅ ២០២៥ | - ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ១១- ធានាថាគ្រូបណ្ដុះបណ្ដាលជំនាញ និងសិស្សទទួលបានការបណ្ដុះបណ្ដាលអំពីបរិស្ថាននិងផលប៉ះពាល់នៃការងារទៅនឹងបរិស្ថាន រួមទាំងជំនាញបៃតង( green skills )។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| គោលដៅ ៣.២.១.៣ អភិវឌ្ឍសួនបច្ចេកទេសនិង | ១- សិក្សានិងបង្កើតសួនបច្ចេកទេសនិងវិជ្ជាជីវៈ នៅតាមតំបន់ឧស្សាហកម្មនិងសេដ្ឋកិច្ចសំខាន់ៗ។ | ២០១៧ ទៅ | - ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងផែនការ |

| | | | |
|---|---|---|---|
| វិជ្ជាជីវៈ នៅតាមតំបន់ឧស្សាហកម្មឬសេដ្ឋកិច្ច ដើម្បីប្រើប្រាស់ទៅតាមសក្តានុពល នូវសម្ភារៈបរិក្ខារ និងគ្រូបណ្តុះបណ្តាល ប្រកបដោយសមត្ថភាពនៅតាមឧស្សាហកម្ម។ | | ២០២៥ | - ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ២- បង្កើតមជ្ឈមណ្ឌលឧត្តមភាព ដើម្បីពង្រឹងគុណភាពបណ្តុះបណ្តាលស្របតាមតម្រូវការទីផ្សារការងារដោយមានការចូលរួមពីភាគីពាក់ព័ន្ធ។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៣- បង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ ដើម្បីសិក្សាលើមុខជំនាញថ្មីៗនិងបំពេញតម្រូវការទីផ្សារការងារទាំងក្នុងប្រទេស ទាំងក្នុងតំបន់។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៤- បង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលធនធានមនុស្សសំដៅបង្កើននិងពង្រឹងសមត្ថភាពមន្ត្រីជំនាញ។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| គោលបំណង៣.១.២ : បង្កើនលទ្ធភាពទទួលបានការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ប្រកបដោយសមធម៌សម្រាប់បង្កើតការងារ | | | |
| គោលដៅ ៣.២.២.១ បង្កើនការចុះឈ្មោះចូលរៀនក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដោយផ្តល់នូវជម្រើស ផ្សេងៗដែលមានភាពបត់បែន។ | ១- បង្កើនលទ្ធភាពទទួលបានការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ តាមរយៈការរៀបចំនិងអនុវត្តការទទួលស្គាល់ការសិក្សាដែលមានពីមុន និងការទទួលស្គាល់សមត្ថភាពនាពេលបច្ចុប្បន្ន ស្របតាមក្របខណ្ឌគុណវុឌ្ឍជាតិកម្ពុជា និងធ្វើការវាយតម្លៃតាមរយៈប្រព័ន្ធវាយតម្លៃជំនាញ។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងទេសចរណ៍<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ២- ពង្រីកកម្មវិធីផ្សព្វផ្សាយអំពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ នៅកន្លែងធ្វើការ ដើម្បីផ្តល់ព័ត៌មានអំពីផលប្រយោជន៍សេដ្ឋកិច្ចដែលនឹងទទួលបានពីការពង្រឹងជំនាញបន្ថែមទៀត។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៣- ពង្រីកកម្មវិធីបណ្តុះបណ្តាលជំនាញតាមលិខិតបញ្ជាក់និងកម្មវិធីស្ពានចម្លងបន្តជំនាញ ដើម្បីផ្តល់លទ្ធភាពដល់សិស្សដែលបានបោះបង់ការសិក្សា និងកម្លាំងពលកម្មដែលកំពុងធ្វើការ ឲ្យបន្តការរៀនសូត្រក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៤- បង្កើនអាហារូបករណ៍សម្រាប់ក្រុមសិស្សគោលដៅ ជាពិសេស សម្រាប់ស្ត្រី ដើម្បីលើកទឹកចិត្តពួកគេឱ្យបន្តការសិក្សាក្នុងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ រួមទាំងការផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់កម្មវិធីស្ពានចម្លងបន្តជំនាញដែលភ្ជាប់នឹងក្របខណ្ឌគុណវុឌ្ឍកម្ពុជាកម្រិតទី២។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងទេសចរណ៍<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |

| | | | |
|---|---|---|---|
| | ៥- ពង្រីកកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ រយៈពេលវែងដល់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ នៅតាមបណ្តារាជធានី ខេត្ត ដែលមិនទាន់មាន។ | ២០១៧<br>ទៅ<br>២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៦- ជំរុញនិងលើកទឹកចិត្តដល់សិស្ស ដែលទទួលបានការបណ្តុះបណ្តាលជំនាញមានលទ្ធភាពអាចបង្កើតមុខរបរដោយខ្លួនឯងតាមរយៈការណែនាំឲ្យមានការយល់ដឹងពីកម្មវិធីឥណទានឬការផ្តល់ឥណទានខ្នាតតូច។ | ២០១៧<br>ទៅ<br>២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៧- រៀបចំនិងអនុវត្តកម្មវិធីបណ្តុះបណ្តាលធនធានមនុស្សសំដៅពលករជំនាញ ដើម្បីធ្វើការចល័តក្នុងតំបន់។ | ២០១៧<br>ទៅ<br>២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងទេសចរណ៍<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| គោលដៅ ៣.២.២.២ បង្កើនឱកាសដល់ប្រជាពលរដ្ឋ ដើម្បីទទួលបាននូវជំនាញសម្រាប់ជីវិតដោយយកចិត្តទុកដាក់ពិសេស លើតម្រូវការរបស់ស្ត្រី ជនបាត់បង់ឱកាស យុវជនទីទ័លក្រ សិស្សដែលបានបោះបង់ការសិក្សា ពលករចំណាកស្រុក និងជនជាតិដើមភាគតិច។ | ១- ផ្តល់អាទិភាពចំពោះស្ត្រី ក្រុមជនងាយរងគ្រោះ យុវជនទីទ័លក្រ សិស្សដែលបានបោះបង់ការសិក្សា ក្រុមជនជាតិ ដើមភាគតិច ពលករចំណាកស្រុក និងអ្នកគ្មានការងារធ្វើឲ្យចូលរៀនក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ តាមរយៈការផ្តល់អាហារូបករណ៍ ប្រាក់ឧបត្ថម្ភ និងអន្តេវាសិកដ្ឋានឲ្យបានគ្រប់គ្រាន់។ | ២០១៧<br>ទៅ<br>២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ២- បង្កើនលទ្ធភាពទទួលបានជំនាញនិងវិញ្ញាបនបត្របញ្ជាក់ ជាពិសេស ពលករចំណាកស្រុកដែលទទួលបានប្រាក់កម្រៃទាប។ | ២០១៧<br>ទៅ<br>២០២៥ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៣- លើកកម្ពស់ការយល់ដឹងអំពីយេនឌ័រនិងអនុវត្តវិធានការសមភាពនិងសមធម៌យេនឌ័រនៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ព្រមទាំងភាគីពាក់ព័ន្ធ។ | ២០១៧<br>ទៅ<br>២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងកិច្ចការនារី<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| គោលដៅ ៣.២.២.៣ បង្កើនគ្រប់មធ្យោបាយនិងយន្តការ ផ្សេងៗដើម្បីពង្រីកការផ្តល់ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ | ១- រៀបចំកម្មវិធីសិក្សាពីចម្ងាយ កម្មវិធីសិក្សាបន្ត ការបណ្តុះបណ្តាលចល័ត និងការបណ្តុះបណ្តាលរយៈពេលខ្លីនៅតាមសហគមន៍ គ្រឹះស្ថានបណ្តុះបណ្តាល សហគ្រាស ឧស្សាហកម្ម ក្រុមហ៊ុន រោងចក្រ ដើម្បីពង្រឹងលទ្ធភាពទទួលបានការបណ្តុះបណ្តាលព្រមទាំងឆ្លើយតបទៅនឹងតម្រូវការជំនាញ។ | ២០១៧<br>ទៅ<br>២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ២- គាំទ្រគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ព្រមទាំងភាគីពាក់ព័ន្ធ ក្នុងការពង្រីកការបណ្តុះបណ្តាលកម្លាំងពលកម្មដោយប្រើប្រាស់ស្តង់ដាជំនាញដែលអនុម័តរួច និងផ្សារភ្ជាប់ទៅនឹងការវាយតម្លៃនៅតាមមជ្ឈមណ្ឌលធ្វើតេស្តថ្នាក់ជាតិ។ | ២០១៧<br>ទៅ<br>២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងទេសចរណ៍<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |

| | | | |
|---|---|---|---|
| ផ្អែកលើក្របខណ្ឌគុណវុឌ្ឍិកម្ពុជាដល់គ្រប់គ្រឹះស្ថាននិងភាគីពាក់ព័ន្ធ។ | ៣- បន្តអនុវត្តយន្តការប្រកួតប្រជែងជំនាញថ្នាក់ជាតិ និងថ្នាក់តំបន់លើបច្ចេកវិទ្យាគំនិតផ្តួចផ្តើមថ្មីៗក្នុងចំណោម សិស្ស និស្សិត អ្នកបច្ចេកទេស វិស្វករ គ្រូបច្ចេកទេស និងសហគ្រិនវ័យក្មេងឲ្យបានទូលំទូលាយ។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងទេសចរណ៍<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| គោលដៅ ៣.២.២.៤ បង្កើនការយល់ដឹងអំពីប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ តាមរយៈការប្រឹក្សាយោបល់ ការណែនាំអំពីអាជីពការងារនិងជំនាញវិជ្ជាជីវៈ ការផ្សព្វផ្សាយរបស់គ្រឹះស្ថាននៅតាមសហគមន៍ និងថ្នាក់ខេត្ត។ | ១- បង្កើនការផ្សព្វផ្សាយតាមមធ្យោបាយផ្សេងៗ ជាពិសេស ការផ្សព្វផ្សាយតាមបណ្តាញសង្គមឲ្យបានគ្រប់គ្រាន់ ដើម្បីលើកកម្ពស់ការ អប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ២- ពង្រឹកសមត្ថភាពនិងលទ្ធភាពព្រមទាំងថវិកាផ្សព្វផ្សាយឲ្យបានគ្រប់គ្រាន់ ដល់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ព្រមទាំងភាគីពាក់ព័ន្ធ ដើម្បីផ្សព្វផ្សាយការបណ្តុះបណ្តាលជំនាញនៅទូទាំងប្រទេស។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៣- រៀបចំយុទ្ធសាស្ត្រទីផ្សារនិងផ្សព្វផ្សាយអំពីជំនាញនៅតាមភូមិ ឃុំ សង្កាត់ សហគមន៍ ដើម្បីទាក់ទាញ សិក្ខាកាម សិស្ស និស្សិត បោះបង់ការសិក្សា ជនក្រីក្រ ជនងាយរងគ្រោះ ជនជាតិភាគតិច ជាពិសេស ស្ត្រីនិងជនជាតិដើមភាគតិច ឲ្យចូលមកសិក្សាក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៤- បង្កើនការផ្សព្វផ្សាយព័ត៌មានស្តីពីវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈនិងការតម្រង់ទិសវិជ្ជាជីវៈ ដល់សិស្សានុសិស្សនៅតាមសាលាមធ្យមសិក្សាចំណេះទូទៅទូទាំងរាជធានី ខេត្ត។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៥- រៀបចំវេទិកាផ្សព្វផ្សាយនិងពិព័រណ៍ស្នាដៃសិស្ស និស្សិតក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| គោលដៅ ៣.២.២.៥ បង្កើតច្រកចេញចូលតែមួយ និងផ្តល់សេវាកម្មផ្សេងៗឲ្យកាន់តែងាយស្រួលជាងមុន ពាក់ព័ន្ធនឹងការអប់រំបណ្តុះបណ្តាល បច្ចេកទេសនិងវិជ្ជាជីវៈ។ | ១- រៀបចំឲ្យមាន "ផ្នែកច្រកចេញចូលតែមួយ" នៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីផ្តល់ព័ត៌មានអំពីអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ រួមមានកម្មវិធីបណ្តុះបណ្តាលជំនាញរយៈពេលខ្លីនិងវែង កម្មវិធីជំនាញថ្មីៗ ការផ្តល់អាហារូបករណ៍ ការហ្វឹកហ្វឺនកូនជាង ការចុះធ្វើកម្មសិក្សា ឱកាសការងារ និងមីក្រូហិរញ្ញវត្ថុ។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ២- រៀបចំឲ្យមានការសិក្សាស្រាវជ្រាវបង្កើតគំនិតច្នៃប្រឌិតថ្មីៗ ការផ្តល់សេវាកម្មទាក់ទងនឹងបច្ចេកវិទ្យាដែលជាតម្រូវការទីផ្សារ ដើម្បីផ្តល់ព័ត៌មានអំពីអាជីពឲ្យបានកាន់តែប្រសើរសម្រាប់សិស្សនិងកម្លាំងពលកម្ម។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៣- បន្តពង្រីក "មជ្ឈមណ្ឌលការងារ" នៅតាមតំបន់ឧស្សាហកម្មផ្សេងៗទៀត ព្រមទាំងពង្រឹងការប្រឹក្សាយោបល់អំពីអាជីពការងារ | ២០១៧ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |

| | | | |
|---|---|---|---|
| | និងជំនាញវិជ្ជាជីវៈ ដើម្បីផ្តល់ជំបូន្មានដ៏មានប្រសិទ្ធភាពសម្រាប់ប្រជាពលរដ្ឋគ្រប់រូប។ | ទៅ<br>២០២៥ | - ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| **គោលបំណង៣.១.៣ : លើកទឹកចិត្តភាពជាដៃគូរវាងរដ្ឋ ឯកជន និងកៀរគរធនធានពីភាគីពាក់ព័ន្ធឲ្យចូលរួមក្នុងការអភិវឌ្ឍនិងធានានិរន្តរភាពនៃប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ** | | | |
| គោលដៅ ៣.២.៣.១<br>ជំរុញភាពជាដៃគូរវាងរដ្ឋ ឯកជន និងភាគីពាក់ព័ន្ធនៅក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ | ១- ជំរុញនិងលើកកម្ពស់ការអនុវត្តយន្តការភាពជាដៃគូរវាងរដ្ឋ ឯកជន និងភាគីពាក់ព័ន្ធ ដើម្បីធានាថាកម្មវិធី អប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ។ | ២០១៧<br>ទៅ<br>២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ២- សហការជាមួយនិយោជកក្នុងការរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីលើកទឹកចិត្តនិយោជក ក្នុងការផ្តល់អាទិភាពដល់អ្នកដាក់ពាក្យចូលបម្រើការងារដែលមានសញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ ស្របតាមក្របខណ្ឌគុណវុឌ្ឍជាតិកម្ពុជា។ | ២០១៧<br>ទៅ<br>២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៣- រៀបចំទម្រង់ផ្សេងៗនៃភាពជាដៃគូរវាងរដ្ឋ ឯកជន និងភាគីពាក់ព័ន្ធដែលគ្របដណ្តប់លើសហគ្រាសខ្នាតតូចនិងមធ្យម វិស័យឧស្សាហកម្ម និងវិស័យផ្សេងទៀត។ | ២០១៧<br>ទៅ<br>២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៤- រៀបចំកម្មវិធីភាពជាដៃគូរវាងរដ្ឋ ឯកជន និងភាគីពាក់ព័ន្ធ ដើម្បីទាក់ទាញការចូលរួមប្រកួតប្រជែងពីវិស័យឯកជន ព្រមទាំងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ក្នុងការបង្កើនគុណភាពនិងប្រសិទ្ធភាពនៃប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ | ២០១៧<br>ទៅ<br>២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៥- បន្តជំរុញគ្រប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ឲ្យមកចុះបញ្ជីនៅក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬនៅមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានីខេត្ត ស្របតាមកម្រិតសិក្សានីមួយៗដែលបានស្នើសុំដោយរាប់បញ្ចូលទាំងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដែលមានច្បាប់អនុញ្ញាតពីក្រសួងឬស្ថាប័នផ្សេង ដើម្បីងាយស្រួលក្នុងការប្រមូលស្ថិតិ ការត្រួតពិនិត្យ និងការអនុវត្តតាមបទដ្ឋានក្របខណ្ឌគុណវុឌ្ឍជាតិកម្ពុជា ស្តង់ដាជាតិសមត្ថភាព ព្រមទាំងការប្រើប្រាស់ប្រព័ន្ធធ្វើតេស្តជំនាញថ្នាក់ជាតិ។ | ២០១៧<br>ទៅ<br>២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| គោលដៅ ៣.២.៣.២<br>ពង្រីកភាពជាដៃគូរវាងរដ្ឋ | ១- បន្តអភិវឌ្ឍកម្មវិធីសិក្សាគ្រប់កម្រិតឲ្យស្របទៅតាមទីផ្សារការងារនិងបច្ចេកវិទ្យាថ្មីៗ ដោយមានការចូលរួមពីស្ថាប័នឯកជន និងភាគីពាក់ព័ន្ធ។ | ២០១៧<br>ទៅ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា |

| | | | |
|---|---|---|---|
| ឯកជននិងភាគីពាក់ព័ន្ធក្នុងការអភិវឌ្ឍកម្មវិធីសិក្សាផ្អែកលើតម្រូវការទីផ្សារការងារ ដើម្បីពង្រឹងជំនាញឲ្យស្របនឹងបច្ចេកវិទ្យាថ្មីៗ និងមានស្រាប់។ | | ២០២៥ | - ក្រសួងទេសចរណ៍<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ២- បន្តបង្កើតក្រុមប្រឹក្សាអភិឌ្ឍន៍ជំនាញតាមវិស័យ ដើម្បីផ្តល់ការប្រឹក្សាយោបល់ និងតម្រង់ទិសក្នុងការអភិវឌ្ឍសមត្ថភាពជំនាញ និងប្រសិទ្ធភាពនៃប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ | ២០១៧<br>ទៅ<br>២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងទេសចរណ៍<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៣- បន្តអភិវឌ្ឍស្តង់ដាជាតិសមត្ថភាព កម្មវិធីសិក្សាផ្អែកលើសមត្ថភាព និងកញ្ចប់ធ្វើតេស្តបញ្ជាក់សមត្ថភាពសម្រាប់គ្រប់វិស័យអាទិភាព។ | ២០១៧<br>ទៅ<br>២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងទេសចរណ៍<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៤- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តកម្មវិធីសិក្សាផ្អែកលើស្តង់ដាជាតិសមត្ថភាពលើគ្រប់វិស័យ។ | ២០១៧<br>ទៅ<br>២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងទេសចរណ៍<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៥- ធានាថាគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ បានបញ្ចូលទស្សនាទានសហគ្រិនភាពក្នុងកម្មវិធីបណ្តុះបណ្តាល ដើម្បីគាំទ្រក្នុងការប្រកបមុខរបរដោយខ្លួនឯង។ | ២០១៧<br>ទៅ<br>២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងទេសចរណ៍<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៦- ពិនិត្យនិងកែសម្រួលច្បាប់ពាក់ព័ន្ធនឹងការហ្វឹកហ្វឺនកូនជាង ឲ្យស្របតាមតម្រូវការនៃការរីកចម្រើនសេដ្ឋកិច្ច។ | ២០១៧<br>ទៅ<br>២០២៥ | -ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>-ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៧- សម្របសម្រួលនិងសហការរវាងគ្រឹះស្ថានបណ្តុះបណ្តាលជាមួយឧស្សាហកម្ម ដើម្បីពង្រឹងគុណភាព និងអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង ទស្សនកិច្ចសិក្សា កម្មវិធីកម្មសិក្សា និងការបណ្តុះបណ្តាលនៅនឹងកន្លែងធ្វើការ។ | ២០១៧<br>ទៅ<br>២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៨- បញ្ចូលជំនាញទន់ក្នុងកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ តាមរយៈការផ្តល់នូវជំនាញដែលអាចផ្ទេរបានសម្រាប់គាំទ្រដល់ការធ្វើការងារនិងការសិក្សាពេញមួយជីវិត ព្រមទាំងជួយដល់សិស្សក្នុងការត្រៀមខ្លួនចូលក្នុងទីផ្សារការងារ។ | ២០១៧<br>ទៅ<br>២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងទេសចរណ៍<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៩- បញ្ចូលសកម្មភាពអប់រំកាយ កីឡា សិល្បៈ និងវប្បធម៌ទៅក្នុងកម្មវិធីសិក្សាព្រមទាំងកសាងហេដ្ឋារចនាសម្ព័ន្ធ ដើម្បីគាំទ្រសកម្មភាព | ២០១៧ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា |

| | | | |
|---|---|---|---|
| | ទាំងនេះនៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ក្នុងគោលបំណងពង្រឹងកាយសម្បទា ការយល់ដឹងពីសិល្បៈ វប្បធម៌បានច្បាស់លាស់ក្នុងដំណាក់កាលនៃនិន្នាការសកលភាវូបនីយកម្មនិងវប្បធម៌ឆ្លងកាត់ ដើម្បីរក្សាបាននូវតម្លៃនៃអត្តសញ្ញាណជាតិ។ | ទៅ ២០២៥ | - ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| គោលដៅ ៣.២.៣.៣ បង្កើតយន្តការសម្របសម្រួល ដើម្បីរៀបចំមូលនិធិជាតិ សម្រាប់ការអភិវឌ្ឍជំនាញពីគ្រប់ភាគី ពាក់ព័ន្ធ | ១- រៀបចំគោលនយោបាយអភិវឌ្ឍជំនាញដែលលើកទឹកចិត្តវិស័យឯកជន ព្រមទាំងភាគីពាក់ព័ន្ធឲ្យចូលរួមអភិវឌ្ឍវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ តាមរយៈការចូលរួមផ្តល់ប្រឹក្សាយោបល់ ការបណ្តុះបណ្តាលជំនាញ ការចូលរួមវិភាគទានហិរញ្ញវត្ថុ ជាតុចូលក្នុងការអភិវឌ្ឍកម្មវិធីសិក្សា និងការបង្កើនឱកាសដល់សិក្ខាកាម សិស្ស និស្សិត អាចធ្វើកម្មសិក្សានៅតាមបណ្តារោងចក្រ សហគ្រាស គ្រឹះស្ថានពាក់ព័ន្ធ។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ២- រៀបចំមូលនិធិជាតិសម្រាប់ការអភិវឌ្ឍជំនាញ ដើម្បីគាំទ្រក្នុងការពង្រឹងជំនាញកម្លាំងពលកម្មផ្អែកលើតម្រូវការទីផ្សារការងារ។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៣- កំណត់គោលដៅមូលនិធិជាតិអភិវឌ្ឍជំនាញឬប្រភពមូលនិធិផ្សេងៗ ដើម្បីគាំទ្រការបណ្តុះបណ្តាលកម្លាំងពលកម្មដែលដឹកនាំដោយឧស្សាហកម្ម ដើម្បីបំពេញតម្រូវការជំនាញកម្រិតខ្ពស់ឬការផ្លាស់ប្តូររបស់បច្ចេកវិទ្យាថ្មីៗ។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| គោលដៅ ៣.២.៣.៤ បន្តរៀបចំគោលការណ៍បង់ថ្លៃសិក្សាសម្រាប់ គ្រឹះស្ថានផ្តល់ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងផ្តល់អាហារូបករណ៍សម្រាប់សិស្ស និស្សិត ក្រីក្រ ជាពិសេស ស្ត្រី និងជនជាតិដើមភាគតិច។ | ១- បន្តជំរុញគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ទាំងរដ្ឋ ទាំងឯកជន ដើម្បីរៀបចំការបង់ថ្លៃសម្រាប់ការបណ្តុះបណ្តាលជំនាញ ដែលស្របទៅនឹងស្តង់ដាជំនាញជាតិ យោងទៅតាមក្របខណ្ឌគុណវុឌ្ឍជាតិកម្ពុជា។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងទេសចរណ៍<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ២- ជំរុញឲ្យគ្រឹះស្ថានប្រើប្រាស់មួយភាគនៃប្រាក់ចំណូលជាកម្មវិធីអាហារូបករណ៍ដល់សិស្សក្រីក្រដែលបានកំណត់អត្តសញ្ញាណដោយក្រសួងនិងស្ថាប័នពាក់ព័ន្ធ។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងទេសចរណ៍<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៣- រៀបចំយន្តការសម្របសម្រួលជាមួយភាគីពាក់ព័ន្ធ ដើម្បីផ្តល់ប្រាក់កម្ចីដល់សិស្ស និស្សិត អាចបន្តការសិក្សាក្នុងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៤- ជំរុញគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ក្នុងការរៀបចំកិច្ចព្រមព្រៀងជាមួយសហគ្រាស ដើម្បីផ្តល់កម្មវិធីបណ្តុះបណ្តាលក្នុងឧស្សាហកម្មឬក្នុងគ្រឹះស្ថាន។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងទេសចរណ៍<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |

| | | | |
|---|---|---|---|
| | ៥- ជំរុញឲ្យដៃគូអភិវឌ្ឍ អង្គការមិនមែនរដ្ឋាភិបាល ក្រុមហ៊ុនឯកជន និងសប្បុរសជន ពិនិត្យមើលលើលទ្ធភាពក្នុងការជួយផ្តល់អាហារូបករណ៍ដល់យុវជនក្រីក្រដែលចូលរៀនក្នុងកម្មវិធីបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងទេសចរណ៍<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| គោលបំណង៣.១.៤ លើកកម្ពស់អភិបាលកិច្ចក្នុងប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ | | | |
| គោលដៅ ៣.២.៤.១ ពង្រឹងយន្តការក្របខណ្ឌគតិយុត្តសម្រាប់ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីភ្ជាប់ការបណ្តុះបណ្តាលជំនាញទៅនឹងតម្រូវការទីផ្សារការងារ។ | ១- បន្តពង្រឹងតួនាទីលេខាធិការដ្ឋានរបស់គណៈកម្មាធិការជាតិបណ្តុះបណ្តាលក្នុងការសម្របសម្រួលជាមួយ ក្រសួង ស្ថាប័ន និងភាគីពាក់ព័ន្ធ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ២- បន្តអនុវត្តគោលការណ៍វិមជ្ឈការក្នុងការគ្រប់គ្រងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីជំរុញបន្ថែមទៀតក្នុងការធ្វើសេចក្តីសម្រេច និងគណនេយ្យភាពសម្រាប់គ្រប់គ្រឹះស្ថាន។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៣- បន្តរៀបចំចងក្រងលិខិតបទដ្ឋានគតិយុត្តស្តីពីតួនាទីនិងភារកិច្ចរបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈស្របតាមបេសសកម្ម និងអាណត្តិរបស់ក្រសួងនិងអង្គភាព។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៤- ពង្រឹងសមត្ថភាពក្នុងការគ្រប់គ្រងគ្រឹះស្ថាន តាមរយៈប្រព័ន្ធកសាងសមត្ថភាពក្នុងភាពជាអ្នកដឹកនាំ គ្រប់គ្រង និងគណនេយ្យភាព។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៥- ពង្រឹងសមត្ថភាពនិងគណនេយ្យភាពនៅតាមអង្គភាពនីមួយៗ ក្នុងការរៀបចំគោលនយោបាយ និងផែនការប្រតិបត្តិការ ប្រចាំឆ្នាំ ការធានាគុណភាព ព្រមទាំងការត្រួតពិនិត្យ តាមដាន និងវាយតម្លៃ។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៦- រៀបចំគោលនយោបាយ បទបញ្ញត្តិ និងអភិបាលកិច្ច ព្រមទាំងពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រងនៅតាមអង្គភាពនីមួយៗ រួមទាំងគ្រឹះស្ថានឯកជន។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៧- ជំរុញគ្រប់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ឲ្យបង្កើតក្រុមការងារទទួលបន្ទុកធ្វើទំនាក់ទំនងជាមួយសមាគមវិជ្ជាជីវៈ ស្ថាប័នផ្តល់សេវាកម្ម រោងចក្រ និងសហគ្រាស ដើម្បីប្រមូលព័ត៌មានអំពីតម្រូវការជំនាញរបស់និយោជក និងជួយរក | ២០១៧ ទៅ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |

| | | | |
|---|---|---|---|
| | ការងារឲ្យសិក្ខាកាម សិស្ស និស្សិតដែលបានបញ្ចប់ការសិក្សាដោយជោគជ័យ។ | ២០២៥ | |
| | ៨- លើកកម្ពស់គុណភាពគ្រប់គ្រងគ្រឹះស្ថាន តាមរយៈការប្រកួតប្រជែង និងរៀបចំឲ្យមានចំណាត់ថ្នាក់ក្នុងចំណោម គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៩- បន្តលើកទឹកចិត្តឲ្យមានកិច្ចសហប្រតិបត្តិការ និងកម្មវិធីផ្លាស់ប្តូរទស្សនកិច្ចសិក្សារវាងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ជាមួយគ្រឹះស្ថានទាំងក្នុងនិងក្រៅប្រទេស។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ១០- បន្តកែលម្អលិខិតបទដ្ឋានគតិយុត្តនិងគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងការចុះបញ្ជិកាគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ឯកជន សមាគម និងអង្គការមិនមែនរដ្ឋាភិបាលឲ្យកាន់តែមានប្រសិទ្ធភាពនិងសុពលភាព។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ១១- ត្រួតពិនិត្យ តាមដាន និងវាយតម្លៃទៅលើភាពឆ្លើយតបនៃប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ១២- រៀបចំគោលនយោបាយអភិវឌ្ឍធនធានមនុស្សដោយយកចិត្តទុកដាក់លើសមភាពយេនឌ័រ ដើម្បីទាក់ទាញគ្រូដែលមានសមត្ថភាព និងរៀបចំកញ្ចប់ផលប្រយោជន៍(មិនមែនត្រឹមតែប្រាក់ឈ្នួលតែប៉ុណ្ណោះទេ)និងលក្ខខណ្ឌការងារល្អប្រសើរផងដែរ។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| គោលដៅ ៣.២.៤.២ រៀបចំយន្តការផ្តល់មូលនិធិផ្អែកលើលទ្ធផលការងារសម្រាប់ប្រតិបត្តិការរបស់ គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ | ១- សិក្សាស្រាវជ្រាវអំពីប្រសិទ្ធភាពនៃយន្តការផ្តល់មូលនិធិសម្រាប់ការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដោយផ្អែកលើលទ្ធផលការងាររបស់ស្ថាប័ន។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ២- សិក្សាស្រាវជ្រាវអំពីជម្រើសគំរូមួយចំនួនសម្រាប់គ្រូដែលឆ្លុះបញ្ចាំងអំពីតម្រូវការបទពិសោធក្នុងវិស័យឧស្សាហកម្មដែលជាធាតុចូលសំខាន់សម្រាប់ការបង្រៀនប្រកបដោយប្រសិទ្ធភាព។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៣- បន្តផ្តល់គោលការណ៍អនុញ្ញាតឲ្យគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ សាធារណៈអាចរកប្រាក់ចំណូលតាមមធ្យោបាយផ្សេងៗសមស្រប ដើម្បីធានាបាននូវនិរន្តរភាពរបស់គ្រឹះស្ថាន។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |

| | | | |
|---|---|---|---|
| | ៤- ផ្តល់មូលនិធិឲ្យបានគ្រប់គ្រាន់សម្រាប់ការអភិវឌ្ឍគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៥- រៀបចំការគ្រប់គ្រងហិរញ្ញវត្ថុរបស់គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសាធារណៈឲ្យមានតម្លាភាព តាមរយៈការកំណត់ឲ្យមានសន្ទស្សន៍បែងចែកប្រាក់ចំណូលដែលបានមកពីប្រភពផ្សេងៗឲ្យបានច្បាស់លាស់ និងបែងចែកខ្ទង់ចំណាយដូចជាការសាងសង់ ការថែទាំអគារ សម្ភារៈបរិក្ខារ និងការលើកទឹកចិត្តផ្សេងៗសម្រាប់មន្ត្រីរាជការ រួមមានបុគ្គលិក សាស្ត្រាចារ្យ និងថ្នាក់ដឹកនាំ។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| គោលដៅ ៣.២.៤.៣ បន្តកែលម្អប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងប្រព័ន្ធព័ត៌មាន ទីផ្សារការងារ ព្រមទាំងពង្រឹងការវិភាគ ព្យាករណ៍ទីផ្សារការងារ និងការស្ទង់មតិលើតម្រូវការជំនាញ។ | ១- អភិវឌ្ឍនិងថែទាំនូវប្រព័ន្ធគ្រប់គ្រងព័ត៌មានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដើម្បីប្រមូលព័ត៌មានពាក់ព័ន្ធនឹងការអភិវឌ្ឍជំនាញ និងប្រព័ន្ធព័ត៌មានទីផ្សារការងារ តាមរយៈកិច្ចសហការជាមួយភាគីពាក់ព័ន្ធ។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងផែនការ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ២- បន្តសិក្សាស្រាវជ្រាវ និងអភិវឌ្ឍប្រព័ន្ធព័ត៌មានទីផ្សារការងារ ព្រមទាំងប្រើប្រាស់លទ្ធផល និងទិន្នន័យសម្រាប់រៀបចំផែនការបណ្តុះបណ្តាលឲ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារ។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងផែនការ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៣- ធ្វើការជាមួយក្រុមប្រឹក្សាជំនាញតាមវិស័យ ប្រមូលមតិត្រឡប់ (feedback) របស់និយោជកលើការបំពេញការងាររបស់កម្លាំងពលកម្ម និងប្រើប្រាស់ព័ត៌មានទាំងនោះជាធាតុចូលសម្រាប់កែលម្អចំណុចខ្វះខាតលើកម្មវិធីបណ្តុះបណ្តាលជំនាញ។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងផែនការ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៤- សិក្សាអំពីតម្រូវការបណ្តុះបណ្តាលជំនាញ និងធ្វើបញ្ជីឈ្មោះមុខរបរ ដាក់លេខកូដសម្គាល់ ដើម្បីជាមូលដ្ឋានសម្រាប់ផ្តល់ការបណ្តុះបណ្តាលដែលស្របតាមតម្រូវការឧស្សាហកម្ម និយោជក និងសហគមន៍។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងផែនការ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៥- ប្រមូល វិភាគ និងរៀបចំរបាយការណ៍ស្តីពីព័ត៌មានរបស់និយោជក និងតម្រូវការកម្លាំងពលកម្មក្នុងពេលអនាគតតាមប្រភេទនៃមុខរបរ ជំនាញ និងវិស័យទាំងក្នុងនិងក្រៅប្រទេស។ | ២០១៧ ទៅ ២០២៥ | - ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងផែនការ<br>- ក្រសួង ស្ថាប័នពាក់ព័ន្ធ |